ក

មាតិកា

I. ខុទ្ទកាល័យព្រះមហាក្សត្រ

១. ព្រះរាជក្រម

០២-១២-២០០៦ -ព្រះរាជក្រម នស/រកម/១២០៦/០២៨ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើឧបសម្ព័ន្ធ ទី ១ ទី ២ ទី ៤ ទី ៧ ទី ៩ ទី ១១ ទី ១២ ទី ១៣អា ទី ១៣បេ ទី ១៥ ទី ១៦ វិសោធនកម្មមាត្រា ១៧ និងពិធីសារទី ១ សម្រាប់អនុវត្តកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡងដ៏ និង សាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការសម្របសម្រួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋ ឆ្លងកាត់ព្រំដែន ***(ត មកពីរាជកិច្ចលេខ ៩១-៩២-៩៣)*** ៨៣០១

២. ព្រះរាជក្រឹត្យ

០៧-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៤៧៩ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ជូននាយទាហាន និងសប្បុរសជន ចំនួន ០៥ រូប ដែលមានគុណបំណាច់ខ្ពស់ក្នុងការបំរើជាតិមាតុភូមិ និងរួមចំណែកជួយអភិវឌ្ឍន៍កងយោធពលខេមរភូមិន្ទ ៨៣៦៨

១៧-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៤៨៨ ស្តីពី ត្រូវបានតាំងស៊ប់ ក្នុងឋានន្តរស័ក្តិអនុមន្ត្រីថ្នាក់លេខ ១១ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ចំនួន ០៦ រូប គិតចាប់ពីថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០០៦ តទៅ ៨៣៦៩

១៧-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៤៨៩ ស្តីពីការតែងតាំង ជាទីប្រឹក្សា នាយកខុទ្ទកាល័យ នាយករងខុទ្ទកាល័យ និងជំនួយការឯកឧត្តម **កែច ពុទ្ធរស្មី** ឧបនាយករដ្ឋមន្ត្រី ចំនួន០៥រូប ៨៣៧០

១៧-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៤៩១ស្តីពីការបញ្ចប់មុខតំណែង និងតែងតាំងមន្ត្រីរាជការ ៨៣៧១

១៧-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៤៩២ ស្តីពីការផ្លាស់ឯកឧត្តម **កែច ពុទ្ធរស្មី** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ម៉ាល់តា ស៊ីប្រ និងស្លូវេនី វិលចូលប្រទេសវិញ ៨៣៧៣

១៧-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៤៩៣ ស្តីពីការផ្លាស់ឯកឧត្តម **ម៉ែម ទិឡារ៉ា** បច្ចុប្បន្នជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព តំណាងអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ និងប្រទេសកាណាដា ឱ្យទទួលភារកិច្ចថ្មី ៨៣៧៤

II_រាជរដ្ឋាភិបាល

អនុក្រឹត្យ

២០-១២-២០០៦ -អនុក្រឹត្យលេខ ១៤៩ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៨៣៧៥
២០-១២-២០០៦ -អនុក្រឹត្យលេខ ១៥០ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៨៣៧៧
២១-១២-២០០៦ -អនុក្រឹត្យលេខ ១៥១ អនក្រ.បក ស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ៨៣៧៩
២២-១២-២០០៦ -អនុក្រឹត្យលេខ ១៥២ អនក្រ.បក ស្តីពីការកែសំរួលអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតគណៈកម្មាធិការសំរុះសំរួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ ៨៣៨១
២២-១២-២០០៦ -អនុក្រឹត្យលេខ ១៥៣ អនក្រ.បក ស្តីពីការបង្កើតក្រុមការងារជាន់ខ្ពស់ប្រព័ន្ធរដ្ឋបាលពតិមានវិទ្យាខេត្ត-ក្រុង ៨៣៨៣
២០-១២-២០០៦ -អនុក្រឹត្យលេខ ៧៨០ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៨៣៨៥
២០-១២-២០០៦ -អនុក្រឹត្យលេខ ៧៨១ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៨៣៨៦
២០-១២-២០០៦ -អនុក្រឹត្យលេខ ៧៨២ អនក្រ.តត ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ ៨៣៨៧
២០-១២-២០០៦ -អនុក្រឹត្យលេខ ៧៨៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៣៨៨
២០-១២-២០០៦ -អនុក្រឹត្យលេខ ៧៨៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៣៨៩
២០-១២-២០០៦ -អនុក្រឹត្យលេខ ៧៨៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៣៩០
២០-១២-២០០៦ -អនុក្រឹត្យលេខ ៧៨៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៣៩២
២០-១២-២០០៦ -អនុក្រឹត្យលេខ ៧៨៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៣៩៣
២០-១២-២០០៦ -អនុក្រឹត្យលេខ ៧៨៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៣៩៤
២០-១២-២០០៦ -អនុក្រឹត្យលេខ ៧៨៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៣៩៦
២០-១២-២០០៦ -អនុក្រឹត្យលេខ ៧៩០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៣៩៧
២០-១២-២០០៦ -អនុក្រឹត្យលេខ ៧៩១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៣៩៨
២០-១២-២០០៦ -អនុក្រឹត្យលេខ ៧៩២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៣៩៩
២០-១២-២០០៦ -អនុក្រឹត្យលេខ ៧៩៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៤០០
២០-១២-២០០៦ -អនុក្រឹត្យលេខ ៧៩៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៤០១
២០-១២-២០០៦ -អនុក្រឹត្យលេខ ៧៩៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៤០២
២០-១២-២០០៦ -អនុក្រឹត្យលេខ ៧៩៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៤០៣

២០-១២-២០០៦ -អនុក្រឹត្យលេខ ៧៩៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៤០៥
២០-១២-២០០៦ -អនុក្រឹត្យលេខ ៧៩៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៤០៦
២០-១២-២០០៦ -អនុក្រឹត្យលេខ ៧៩៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៤០៨
២០-១២-២០០៦ -អនុក្រឹត្យលេខ ៨០០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៤០៩
២០-១២-២០០៦ -អនុក្រឹត្យលេខ ៨០១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៨៤១០
២០-១២-២០០៦ -អនុក្រឹត្យលេខ ៨០២ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៨៤១១
២១-១២-២០០៦ -អនុក្រឹត្យលេខ ៨០៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៤១២
២១-១២-២០០៦ -អនុក្រឹត្យលេខ ៨០៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៨៤១៣
២១-១២-២០០៦ -អនុក្រឹត្យលេខ ៨០៥ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ៨៤១៨
២១-១២-២០០៦ -អនុក្រឹត្យលេខ ៨០៦ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៨៤២០
២២-១២-២០០៦ -អនុក្រឹត្យលេខ ៨០៧ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៨៤២១

III. ការងារបណ្តាក្រសួង

១. ទីស្តីការក្រសួងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៨-១២-២០០៦ -ប្រកាសលេខ ១២៨៥ ឧរថ.កឧ.ប្រក អនុញ្ញាតឱ្យក្រុមហ៊ុន **ហូយៀ (ខេមបូឌា) ហ្គាមេន លីមីធីត** បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់នាំចេញ" ដែលមានឈ្មោះថា "ហូយៀ (ខេមបូឌា) ហ្គាមេន លីមីធីត សាខា ទី ១" ៨៤២៣
២០-១២-២០០៦ -ប្រកាសលេខ ១២៨៨ ឧរថ.កឧ.ប្រក អនុញ្ញាតឱ្យក្រុមហ៊ុន **ម៉ាកាឡូត ហ្គាមេន (ខេមបូឌា)** បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះ ថា " ម៉ាកាឡូត ហ្គាមេន (ខេមបូឌា) សាខា ទី ១" ៨៤២៥
២០-១២-២០០៦ -ប្រកាសលេខ ១២៨៩ ឧរថ.កឧ.ប្រក អនុញ្ញាតឱ្យក្រុមហ៊ុន **ម៉ាកាឡូត ហ្គាមេន (ខេមបូឌា)** បង្កើតសាខារោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា " ម៉ាកាឡូត ហ្គាមេន (ខេមបូឌា) សាខា ទី ២" ៨៤២៧
២០-១២-២០០៦ -ប្រកាសលេខ ១២៩០ ឧរថ.កឧ.ប្រក អនុញ្ញាតឱ្យក្រុមហ៊ុន **ម៉ាកាឡូត ហ្គាមេន (ខេមបូឌា)** បង្កើតសាខារោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា " ម៉ាកាឡូត ហ្គាមេន (ខេមបូឌា) សាខា ទី ៣" ៨៤២៩

២. ទីស្តីការក្រសួងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

២០-១២-២០០៦ -ប្រកាសលេខ ១៧២១ ប្រក ស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយ ៨៤៣១

ព្រះរាជក្រម

នស/រកម/១២០៦/០២៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើឧបសម្ព័ន្ធទី១ ទី២ ទី៤ ទី៧ ទី៩ ទី១១ ទី១២ ទី១៣អា ទី១៣បេ ទី១៥ ទី១៦ វិសោធនកម្មមាត្រា១៧ និងពិធីសារទី១ សម្រាប់អនុវត្តកិច្ចព្រមព្រៀងរវាងនិងក្នុងរង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាសាធារណរដ្ឋប្រជាមានិតចិន សាធា-

រណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៏ និង សាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការសម្រួលការដឹកជញ្ជូនទំនិញនិងពលរដ្ឋឆ្លងកាត់ព្រំដែន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៥ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើឧបសម្ព័ន្ធទី ១ ទី ២ ទី ៤ ទី ៧ ទី ៩ ទី ១១ ទី ១២ ទី ១៣អា ទី ១៣បេ ទី ១៥ ទី ១៦ វិសោធនកម្មមាត្រា ១៧ និងពិធីសារទី ១ សម្រាប់អនុវត្តកិច្ចព្រមព្រៀង រវាងនិងក្នុង រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាមស្តីពីការសម្រួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន

មាត្រា ១.-

អនុម័តយល់ព្រមលើឧបសម្ព័ន្ធទី ២ ទី ៤ ទី ៧ ទី ១១ ទី ១២ ទី ១៣អា ទី ១៥ វិសោធនកម្មមាត្រា ១៧ និងពិធីសារទី ១ ដែលធ្វើនៅទីក្រុងភ្នំពេញ នាថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៤ និងឧបសម្ព័ន្ធទី ១ ទី ៩ ទី ១៣បេ ទី ១៦ ដែលធ្វើនៅទីក្រុងវៀងច័ន្ទ នាថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៤ សម្រាប់អនុវត្តកិច្ចព្រមព្រៀង រវាងនិងក្នុង រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាម

ស្តីពីការសម្រួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តឧបសម្ព័ន្ធពិធីសារ និងវិសោធនកម្មនៃកិច្ចព្រមព្រៀងនេះ ។

រាជធានីភ្នំពេញថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសម្តេច

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

នស.រកម.១២០៦.៩០១

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

ហត្ថលេខា

ស៊ុន ចាន់ថុល

លេខ : ៤៥០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

(ត មកពីរាជកិច្ចលេខ ៩១-៩២-៩៣)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

កិច្ចព្រមព្រៀង

រវាង និងក្នុងរង្វង់

រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន
សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា
ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម

ស្តីអំពីការសំរបសំរួលនូវការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន

នាយកដ្ឋានផែនការ

ឆ្នាំ ២០០៦

ព្រះរាជក្រម

នស/រកម/០១០៣/០០២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយម វៀតណាមស្តីពីការសម្រួលនៃការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាល ទី ២ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គ លើកទី ៨ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់
ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាង
និងក្នុងរង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិត
ប្រជាធិបតេយ្យឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និង សាធារណរដ្ឋសង្គមនិយម
វៀតណាម ស្តីពីការសម្រួលនៃការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន

មាត្រា ១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងនិងក្នុងរង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការសម្រួលនៃការដឹកជញ្ជូនទំនិញនិងពលរដ្ឋឆ្លងកាត់ព្រំដែន ដែលធ្វើនៅទីក្រុងយ៉ាំងហ្គូន ប្រទេសមីយ៉ាន់ម៉ា នាថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០១ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០៣

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

៣រល.០៣.០១.០៤០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ហត្ថលេខា

ឃី តាំងលីម

លេខៈ ២៦ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែមករា ឆ្នាំ២០០៣

អគ្គលេខាធិការរាជរដ្ឋាភិបាល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :១៥...សាធណ.កបច

សេចក្តីថ្លែងហេតុ

នៃសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាង និងក្នុងចំណោមរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពី ការសម្រួលនៃការដឹកជញ្ជូនទំនិញ និងពលរដ្ឋ ឆ្លងកាត់ព្រំដែន

ក- ដើមឡើយកិច្ចព្រមព្រៀងនេះ មាន ១០ ផ្នែក ៤៥ មាត្រា និងមានឧបសម្ព័ន្ធ ១៦ និងពិធីសារ (០៣) ត្រូវបានចុះហត្ថលេខាថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ ដោយសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ។ ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខា ចូលក្នុងកិច្ចព្រមព្រៀងនេះ នៅពេលដែលកិច្ចព្រមព្រៀងនេះ ត្រូវបានគេធ្វើវិសោធនកម្ម នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០១ នៅទីក្រុង យ៉ាងហ្គូន ប្រទេសមីយ៉ាន់ម៉ា ដើម្បីឱ្យប្រទេសក្នុងមហាអនុតំបន់ទន្លេមេគង្គអាចចូលបាន ។ កិច្ចព្រមព្រៀងនឹងត្រូវប្តូរឈ្មោះជាស្វ័យប្រវត្តិ ដោយរួមបញ្ចូលភាគីចុះហត្ថលេខាថ្មីក្នុងការសម្រួលដឹកជញ្ជូនពលរដ្ឋ និងទំនិញ ឆ្លងកាត់ព្រំដែន ។ ឧបសម្ព័ន្ធ និងពិធីសារទាំងអស់ ដែលលំអិតបច្ចេកទេសសម្រាប់អនុវត្តការសម្រួលដឹកជញ្ជូន ឆ្លងកាត់ព្រំដែន ត្រូវរៀបចំឡើងធ្វើការជជែកពិភាក្សា និងចុះហត្ថលេខាជាបន្តបន្ទាប់ ។

ខ- *គោលបំណងនៃកិច្ចព្រមព្រៀង:*

- សម្រួលការដឹកជញ្ជូន កាត់បន្ថយ និងធ្វើឱ្យស៊ីសង្វាក់គ្នាខាងផ្លូវច្បាប់ បទប្បញ្ញត្តិ នីតិវិធី និងល័ក្ខខ័ណ្ឌនានាទាក់ទងទៅនឹង ការដឹកជញ្ជូនទំនិញ និងប្រជាពលរដ្ឋឆ្លងកាត់ព្រំដែន និងជំរុញការដឹកជញ្ជូន ពហុរូបភាព ។
- អភិវឌ្ឍ និងថែរក្សា ប្រព័ន្ធដឹកជញ្ជូន និងគមនាគមន៍មួយ ដែលមានផលប្រយោជន៍ទៅវិញទៅមករលូនរហ័ស សមហេតុសមផលត្រឹមត្រូវ និងមានប្រសិទ្ធភាព បង្កើនការរួមសហការគ្នា លើវិស័យដឹកជញ្ជូនតាមផ្លូវគោក ការសម្រួលចរាចរ ទំនិញ និងពលរដ្ឋក្នុងផលប្រយោជន៍រួមគ្នា ។

គ- *ខ្លឹមសារ និងចំណុចសំខាន់ៗ :*

វិសាលភាពនៃកិច្ចព្រមព្រៀងអនុវត្តចំពោះការដឹកជញ្ជូនទំនិញ និងពលរដ្ឋ :

- ចូល ចេញ ឆ្លងកាត់ព្រំដែន ឬឆ្លងកាត់ទឹកដី នៃភាគីចុះកិច្ចសន្យាណាមួយ
- មានការដឹកជញ្ជូនតាមរថយន្តមួយគ្រឿងឬច្រើនគ្រឿង តាមផ្លូវថ្នល់ (រាប់បញ្ចូលទាំងការឆ្លងកាត់ទន្លេតាមសាឡាងចម្លងទៅទីណា ដែលពុំមានស្ពានឆ្លង)
- ដឹកជញ្ជូនពាណិជ្ជកម្ម ដោយអាជីវករដឹកជញ្ជូនសាធារណៈ ឬជាឯកជនដឹកជញ្ជូនផ្ទាល់ខ្លួន ឬសម្រាប់ជួល ។

ចំណុចសំខាន់ពិសេសសម្រាប់កិច្ចព្រមព្រៀងគឺ <u>ការសម្រួលបែបបទឆ្លងកាត់ព្រំដែន</u> ដែលត្រូវកាត់បន្ថយ និងធ្វើឱ្យបានឆាប់រហ័ស នូវបែបបទតាមព្រំដែនដូចជា:

ក-ការត្រួតពិនិត្យរួមគ្នាតែមួយលើក: (Single Window Inspection or One Window Inspection)

ការត្រួតពិនិត្យផ្សេងៗ ត្រូវអនុវត្តរួមគ្នា និងព្រមពេលជាមួយគ្នា ដោយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធរៀងៗខ្លួន (គយ-ប៉ូលីសអន្តោប្រវេសន៍-ពាណិជ្ជកម្ម-សុខាភិបាល ។ល។) ទៅលើពលរដ្ឋ យានយន្ត និងទំនិញរួមគ្នា (លិខិតឆ្លងដែន ទិដ្ឋាការ ប័ណ្ណ បើកបរ សុខភាព និងការពិនិត្យរោគរាតត្បាត ការចុះបញ្ជី លក្ខណបច្ចេកទេសយានយន្ត ការធានារ៉ាប់រង គយរដ្ឋាករ គុណភាព ភូតគាមអនាម័យ ការការពាររុក្ខជាតិ បសុពេទ្យ) ។ល។

ខ- ការត្រួតពិនិត្យស្របគ្នាពេលតែមួយ: (Single Stop Inspection or One Stop Inspection)

អាជ្ញាធរជាតិដែលស្ថិតនៅជាប់គ្នាទាំងពីរ នឹងត្រូវអនុវត្តការត្រួតពិនិត្យរួមគ្នា និងព្រមពេលជាមួយគ្នា ត្រូវជួយគ្នាទៅវិញទៅមកតាមលទ្ធភាព។ នៅកន្លែងណាដែលពុំអាចឱ្យសាងសង់បាននូវប៉ុស្តិ៍ត្រួតពិនិត្យ ដែលស្ថិតនៅជាប់រួមជាមួយគ្នានៅតាមព្រំដែនរេន មន្ត្រីត្រួតពិនិត្យនៃភាគីកិច្ចសន្យាមួយ ត្រូវបានអនុញ្ញាតធ្វើសកម្មភាពការងារត្រួតពិនិត្យរបស់ខ្លួននៅលើទឹកដីនៃភាគីចុះកិច្ចសន្យាមួយផ្សេងទៀត ។

គ- ការសម្របសម្រួលពេលម៉ោងធ្វើការងារ: របស់អាជ្ញាធរត្រួតពិនិត្យការឆ្លងកាត់ព្រំដែន ដែលនៅជាប់គ្នា ។

ឃ- ការប្តូរគ្នាជាមុន នូវព័ត៌មាន និងការជម្រះបែបបទ: នៃទំនិញ និងពលរដ្ឋ ។

កិច្ចព្រមព្រៀងបានកំណត់ល័ក្ខខ័ណ្ឌ និងបែបបទនៃការចេញទិដ្ឋាការ ក្នុងការដឹកជញ្ជូនប្រជាពលរដ្ឋឆ្លងកាត់ព្រំដែនទាំងឡាយ ដែលធ្វើអាជីវកម្មដឹកជញ្ជូន បែបបទ តម្រូវការ និងការស្នើសុំទិដ្ឋាការឆ្លងកាត់ ចេញ ចូល ច្រើនដង រយៈពេលវែង ។ល។ ចំពោះការដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែន ត្រូវលើកលែងចេញពីការត្រួតពិនិត្យជាក់ស្តែងរបស់គយ ការតម្កល់ប្រាក់ធានា និងការអមដំណើរនឹងត្រូវរៀបចំឡើងនូវរបបជម្រះបែបបទគយខាងក្នុងប្រទេស និងឆ្លងកាត់តាមបែបបទថ្មីៗ ។ល។

កិច្ចព្រមព្រៀងកំណត់ការផ្តល់ឱ្យដោយសេរី សម្រាប់ការដឹកជញ្ជូនឆ្លងកាត់ (ចេញ) ឆ្ពោះទៅ ឬត្រឡប់(ចូល) ទឹកដីនៃភាគីចុះកិច្ចសន្យានីមួយៗ នឹងត្រូវលើកលែងមិនឱ្យមានជាប់ពន្ធគយ ពន្ធដារផ្សេងៗ និងការចំណាយមិនចាំបាច់នានា។ ការបង់ថ្លៃសេវាឆ្លងកាត់ត្រូវចរចា និងអនុវត្តបណ្តើរៗ ជាពីរជំហាន ហើយចុងក្រោយគឺឆ្លងកាត់ដោយមិនមានការបង់ថ្លៃ។

ភាគីចុះកិច្ចសន្យានឹងត្រូវគោរពតាម កិច្ចព្រមព្រៀងអន្តរជាតិ ដែលស្របទៅនឹងបទប្បញ្ញត្តិ នៃអង្គការសុខភាពពិភពលោកអង្គការម្ហូបអាហារ និងកសិកម្ម និងការិយាល័យអន្តរជាតិនៃរោគរាតត្បាតរបស់សត្វ ក្នុងការអនុវត្តការត្រួតពិនិត្យទំនិញឆ្លងកាត់ព្រំដែន និងការត្រួតពិនិត្យភូតគាមអនាម័យ និងបសុពេទ្យ ។

កិច្ចព្រមព្រៀង មិនអនុវត្តទៅលើការដឹកជញ្ជូន ទំនិញគ្រោះថ្នាក់ នឹងផ្តល់អាទិភាពពិសេសក្នុងការដឹកជញ្ជូនទំនិញងាយខូចគុណភាព នឹងត្រូវរៀបចំបំពេញ នឹងជម្រះបែបបទគយឆ្លងកាត់ព្រំដែនឱ្យបានរហ័ស ដើម្បីឱ្យទំនិញទាំងនេះចៀសផុតពីការយឺតយ៉ាវ ។

ត្រូវអនុញ្ញាតឱ្យយកចូលមកក្នុងទឹកដីរបស់ខ្លួន ទាំងរថយន្តចង្កូតឆ្វេង ឬចង្កូតស្តាំ (ឬរថយន្តធ្វើពាណិជ្ជកម្ម រថយន្តជាលំខ្លួន ឬឯកជន) ដែលចុះបានបញ្ជីដោយភាគីដទៃផ្សេងទៀត ។ យានយន្តទាំងឡាយ ដែលធ្វើចរាចរឆ្លងកាត់ព្រំដែន ត្រូវចុះបញ្ជីនៅក្នុងប្រទេសដើមរបស់ខ្លួន នឹងត្រូវមានបញ្ជាក់សញ្ញាសម្គាល់គ្រប់គ្រាន់ (សញ្ញាពាណិជ្ជកម្មនៃរោងចក្រផលិត លេខតួ និងលេខម៉ាស៊ីន) មានវិញ្ញាបនបត្រចុះបញ្ជី មានបំពាក់លេខចុះបញ្ជីនៅលើផ្ទាកលេខមួយ ពាក់នៅខាងក្រោយ និងខាងមុខ នឹងបំពាក់នូវសញ្ញាសម្គាល់ប្រទេសដែលយានយន្តបានចុះបញ្ជីត្រឹមត្រូវ ។

យានយន្ត និងកុងធីន័រ ក៏ត្រូវបំពាក់គ្រប់គ្រាន់នូវសម្ភារៈសុវត្ថិភាព នឹងមានកម្រិតការបញ្ចេញផ្សែងឱ្យត្រឹមត្រូវតាមស្តង់ដារ ដែលមានជាធរមាននៅក្នុងប្រទេសដើមរបស់គេ។ យានយន្តដែលធ្វើដំណើរទៅកាន់ទឹកដីនៃភាគីដទៃ ក៏ត្រូវតែគោរពផងដែរតាមស្តង់ដារបច្ចេកទេសនៃប្រទេសសាមី ដែលទាក់ទងទៅនឹងទម្ងន់សរុប បន្ទុកភ្លៅ និងទំហំ ខ្នាតនៃយាន ។ល។

យានយន្តឆ្លងកាត់ត្រូវមានដំណើរការខាងបច្ចេកទេស ។ ប្រទេសដើមជាអ្នកទទួលបន្ទុក ក្នុងការត្រួតពិនិត្យលក្ខណបច្ចេកទេសរបស់យានយន្ត ដែលចុះបញ្ជីនៅក្នុងទឹកដីរបស់ខ្លួន នឹងត្រូវចេញវិញ្ញាបនបត្រត្រួតពិនិត្យ លក្ខណបច្ចេកទេសយានយន្ត។ ភាគីដទៃទៀត ត្រូវទទួលស្គាល់នូវវិញ្ញាបនបត្រនេះ ។ ផ្លាកសញ្ញា បទប្បញ្ញត្តិចរាចរផ្លូវគោក និងស្តង់ដារត្រូវអនុម័ត និងអនុវត្តជាជំហាន១ឱ្យឯកភាពគ្នា។

រថយន្ត ដែលធ្វើដំណើរឆ្លោះទៅកាន់ដែនដីនៃភាគីផ្សេងទៀត ត្រូវអនុវត្តទៅតាមកាតព្វកិច្ច នឹងមានប័ណ្ណធានារ៉ាប់រងទៅលើភាគីទី ៣ ជាដាច់ខាត ។

ត្រូវទទួលស្គាល់ប័ណ្ណបើកបរ ដែលចេញឱ្យដោយភាគីផ្សេង១ទៀត ស្របទៅតាមកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ប័ណ្ណបើកបរក្នុងស្រុក ចេញដោយបណ្តាប្រទេសអាស៊ាន ។

ត្រូវផ្តល់ឱ្យនូវការយកចូលជាបណ្តោះអាសន្ន នូវរថយន្ត (និងប្រេងឥន្ធនៈ ដែលមានក្នុងធុងប្រេងផ្គត់ផ្គង់របស់វា ប្រេងរំអិល សម្ភារៈសម្រាប់ជួសជុល និងគ្រឿងបន្លាស់ ទៅតាមចំនួនមួយដ៏សមរម្យ) ដែលបានចុះបញ្ជីនៅភាគីដទៃទៀត ដោយពុំចាំបាច់បង់ពន្ធគយ និងពន្ធនាំចូល ដោយពុំមានការតម្កល់ទុកប្រាក់សម្រាប់ធានាក្នុងការបង់ពន្ធគយ នឹងអាចចេញចូលដោយសេរីរួចពីបំរាម និងល័ក្ខខ័ណ្ឌសម្រាប់ការនាំចេញជាថ្មី ។ល។

សិទ្ធិនៃការធ្វើចរាចរឆ្លងកាត់ នឹងត្រូវធ្វើឡើងជាបន្តបន្ទាប់ ជាពីរជំហាន :

ជំហានទី ១ : ភាគីចុះកិច្ចសន្យាមួយ អាចធានាឱ្យមានការដឹកជញ្ជូន ដូចខាងក្រោម :

(ក) ការដឹកជញ្ជូនឆ្លងកាត់ កាត់តាមទឹកដីភាគីចុះកិច្ចសន្យាដទៃទៀត

(ខ) ការឆ្លងព្រំដែន ចូលទៅក្នុងទឹកដីភាគីចុះកិច្ចសន្យាដទៃទៀត

(គ) ការឆ្លងព្រំដែន ចេញពីទឹកដីភាគីចុះកិច្ចសន្យាដទៃទៀត

ជំហានទី ២ : អាជីវករដឹកជញ្ជូនដែលបានបង្កើតឡើង នៅក្នុងភាគីចុះកិច្ចសន្យាមួយ អាចទទួលខុសត្រូវក្នុងការធ្វើអាជីវកម្មដឹកជញ្ជូន ចូលទៅក្នុង ចេញពី ឬក៏ឆ្លងកាត់ទឹកដីនៃភាគីចុះកិច្ចសន្យាដទៃទៀត។

ប៉ុន្តែ ការដឹកជញ្ជូនផ្ទៃក្នុង អាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាតពិសេសណាមួយពីប្រទេសសាមី ។

អាជីវករដឹកជញ្ជូន ត្រូវមានអាជ្ញាប័ណ្ណសម្រាប់ការធ្វើអាជីវកម្មដឹកជញ្ជូនឆ្លងកាត់ ដែលចេញឱ្យដោយប្រទេសដើមរបស់ខ្លួន។ ប្រទេសសាមី ត្រូវទទួលស្គាល់អាជ្ញាប័ណ្ណអាជីវកម្ម ដែលចេញឱ្យដោយប្រទេសដើម ។

អាជីវករដឹកជញ្ជូន ដែលបានទទួលអាជ្ញាប័ណ្ណយ៉ាងត្រឹមត្រូវ សម្រាប់ធ្វើអាជីវកម្មដឹកជញ្ជូនឆ្លងកាត់ព្រំដែន នៅឯប្រទេសដើមរបស់ខ្លួន នឹងត្រូវទទួលសិទ្ធិធ្វើអាជីវកម្មដឹកជញ្ជូនឆ្លងកាត់ព្រំដែន។ ប្រទេសសាមី ត្រូវជួយផ្តល់ការអនុញ្ញាតទៅអាជីវករដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដើម្បីបង្កើតការិយាល័យតំណាង ក្នុងគោលបំណងសម្រួលការធ្វើអាជីវកម្មដឹកជញ្ជូនរបស់ខ្លួន ។

ប្រតិបត្តិការដឹកជញ្ជូន ត្រូវបានអនុញ្ញាតជាបន្តបន្ទាប់ ជាពីរជំហាន :

ជំហានទី ១ : បរិមាណដឹកជញ្ជូន អាចត្រូវគេកំណត់ឡើងក្នុងពិធីសារទី ៣។ រយៈពេលនៃការអនុវត្តជំហានទី ១ នឹងត្រូវគេកំណត់ក្នុងពិធីសារទី ៣ គណៈកម្មាធិការជាតិសម្រាប់សម្រួលការដឹកជញ្ជូន នៃភាគីចុះ

កិច្ចសន្យានីមួយៗត្រូវបូកគ្នា និងចេញឱ្យនូវបរិមាណដែលអនុញ្ញាត ហើយដែលមានការព្រមព្រៀងគ្នារៀងរាល់ឆ្នាំ ។

ជំហានទី ២ : បរិមាណ និងសមត្ថភាពនៃការធ្វើអាជីវកម្មដឹកជញ្ជូន ស្របតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ នឹងមិនត្រូវឱ្យមានការតឹងរឹង ជាជាងខ្លឹមសារដែលមានចែងក្នុងកិច្ចព្រមព្រៀងឡើយ ។

ល័ក្ខខ័ណ្ឌនៃការដឹកជញ្ជូន នឹងត្រូវរៀបចំទៅតាមបទប្បញ្ញត្តិ ដែលកំណត់នៅក្នុងឧបសម្ពន្ធទី ១០ ។ ការកំណត់តម្លៃសម្រាប់ការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ត្រូវអនុវត្តដោយសេរី និងតាមកម្លាំងទីផ្សារ ប៉ុន្តែត្រូវដាក់កម្រិតក្នុងការប្រមូលផ្តុំសហគ្រាស និងមានការពិនិត្យពិច័យពីគណៈកម្មការរួម ដើម្បីចៀសវាងការដាក់ថ្លៃឈ្នួលខ្ពស់ខ្លាំងពេក ឬទាបខ្លាំងពេក ។

ផ្លូវដឹកជញ្ជូន និងចំណុចនានា សម្រាប់ការចូល និងការចេញ ត្រូវកំណត់ក្នុងពិធីសារទី ១ ។ ការស្ថាបនា ឬការស្ថាបនាជាថ្មីឡើងវិញនូវផ្លូវថ្នល់ (គិតទាំងស្ពាន) ដែលតភ្ជាប់ប្រទេសទាំងឡាយ និងដែលបង្ហាញនៅក្នុងពិធីសារទី ១ ត្រូវធ្វើទៅតាមស្តង់ដារគំនូសប្លង់នៃផ្លូវ និងស្ពាន ក្នុងក្របខ័ណ្ឌនៃកម្មវិធីសាធារណការរបស់ជាតិ ឬក៏ទៅតាមការផ្តល់ថវិកាជាអន្តរជាតិ ។ ការស្ថាបនា ឬការស្ថាបនាឡើងវិញនឹងត្រូវធ្វើឡើង ដោយអនុលោមទៅតាមលក្ខណៈអប្បបរមា ដូចកំណត់ក្នុងឧបសម្ពន្ធ ទី ១១ ទៅតាមកម្រិតអនុញ្ញាត និងស្របទៅតាមប្រភពថវិកាដែលមាន។

ត្រូវធានាថាផ្លូវថ្នល់ដែលបានឯកភាពគ្នា ត្រូវមានសុវត្ថិភាព សន្តិសុខ និងស្ថិតក្នុងល័ក្ខខ័ណ្ឌ និងត្រូវរ៉ាប់រងក្នុងការអនុវត្ត ការជួសជុលនានាដែលចាំបាច់ ការដាក់ផ្លាកសញ្ញា និងភ្លើងសញ្ញានានា ស្របទៅតាមស្តង់ដារជាជំហាន១ ដូចបានកំណត់ក្នុងឧបសម្ពន្ធទី ៧ ។

ត្រូវទទួលរ៉ាប់រង ក្នុងការស្ថាបនា ឬធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ពន្ធ ដែលត្រូវការនៅចំណុចឆ្លងកាត់ព្រំដែន និងក្នុងការរៀបចំចាត់តាំងមន្ត្រីរបស់ខ្លួនឱ្យបម្រើការនៅទីនោះ ដើម្បីធានាការបំពេញបែបបទឆ្លងកាត់ព្រំដែនឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព ដូចមានចែងក្នុងឧបសម្ពន្ធទី ១២ ។

ត្រូវបង្កើតឡើងនូវគណៈកម្មាធិការជាតិអចិន្ត្រៃយ៍សម្រួលការដឹកជញ្ជូន ដែលត្រូវដឹកនាំដោយរដ្ឋមន្ត្រី ឬអនុរដ្ឋមន្ត្រីមួយរូប ឬមន្ត្រីដែលមានឋានៈស្មើ ដែលមានតំណាងគ្រប់ផ្នែករបស់ក្រសួង-ស្ថាប័នជាប់ពាក់ព័ន្ធ ក្នុងការអនុវត្តកិច្ចព្រមព្រៀងឱ្យចូលរួមជាសមាជិក ។ តំណាងទាំងឡាយ នៃគណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូននឹងរួមគ្នាបង្កើតឡើងជាគណៈកម្មាធិការតំបន់មួយ។

គណៈកម្មាធិការរួមនេះនឹងតាមដានត្រួតពិនិត្យ និងវាយតម្លៃ នូវការប្រព្រឹត្តទៅនៃកិច្ចព្រមព្រៀង និងប្រើប្រាស់ជាវេទិកាសម្រាប់ជជែក ពិភាក្សា និងដោះស្រាយទំនាស់តាមគោលការណ៍សន្តិវិធី និងជាវេទិកាផ្តល់ដំបូន្មានទៅកាន់ភាគីចុះកិច្ចសន្យា ព្រមទាំងរៀបចំសំណើធ្វើវិសោធនកម្មកិច្ចព្រមព្រៀង។

ប្រជាពលរដ្ឋ អាជីវករដឹកជញ្ជូន និងយានយន្ត ត្រូវអនុវត្តទៅតាមច្បាប់ និងបទប្បញ្ញត្តិទាំងឡាយ ដែលនៅជាធរមានក្នុងទឹកដីនៃប្រទេសសាមី ។ នៅពេលដែលមានការរំលោភច្បាប់ ត្រូវអនុវត្តច្បាប់ និងបទប្បញ្ញត្តិជាមូលដ្ឋានរបស់អាជ្ញាធរប្រទេសជាសាមី ។ ប្រទេសសាមី អាចបដិសេធជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍នូវការចូលទៅក្នុងដែនដីរបស់ខ្លួន ចំពោះជនណាមួយ អ្នកបើកបរណាមួយ អាជីវករដឹកជញ្ជូនណាមួយ ឬក៏យានយន្តមួយ ដែលបានរំលោភបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង ឬក៏ច្បាប់ និងបទប្បញ្ញត្តិជាតិរបស់ប្រទេសខ្លួន ។

ត្រូវបង្កើតឱ្យមានសៀវភៅកម្រងច្បាប់ជាតិ បទប្បញ្ញត្តិ នីតិវិធី និងពត៌មានបច្ចេកទេសជាភាសាអង់គ្លេស អំពីការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ។

ត្រូវធានាផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះបំផុត ចំពោះយានយន្ត ទំនិញ និងពលរដ្ឋ នៃភាគីផ្សេងទៀតដោយស្មើភាព និងមិនតិចជាងការផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះបំផុតទៅលើប្រទេសទី ៣ ណាមួយ ក្នុងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន។

ប្រទេសសាមី ត្រូវចាត់វិធានការជួយសង្គ្រោះគ្រប់បែបយ៉ាង និងត្រូវជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ច នៃប្រទេសដើមឱ្យបានឆាប់រហ័សបំផុត ក្នុងករណីមានគ្រោះថ្នាក់ចរាចរ ដែលពាក់ព័ន្ធដល់ប្រជាពលរដ្ឋ អាជីវករដឹកជញ្ជូន យានយន្ត ឬទំនិញពីភាគីផ្សេងទៀត ។

ត្រូវទទួលរ៉ាប់រងក្នុងការជំរុញប្រតិបត្តិការពហុដឹកជញ្ជូន តាមរយៈការអនុវត្តរបបទទួលខុសត្រូវពហុដឹកជញ្ជូន មានសណ្ឋានតែមួយ និងកំណត់បរិមាណជាអប្បបរមានូវលក្ខណសម្បត្តិ ដែលតម្រូវឱ្យមានសម្រាប់អាជីវកម្មពហុដឹកជញ្ជូន ដែលមានកំណត់ក្នុងឧបសម្ព័ន្ធទី ១៣ អា-បេ ។

ត្រូវរៀបចំរបបគយក្នុងពិធីរពិសេសមួយ និងឯកភាពគ្នារក្សាទុកការចំណាយ និងពេលវេលាយឺតយ៉ាវឱ្យដល់កម្រិតជាអប្បបរមា។

ភាគីនីមួយៗ ត្រូវទទួលរ៉ាប់រងបន្ថែមទៀតក្នុងការ :

១-កំណត់ចំនួនឯកសារ និងកាត់បន្ថយនូវនីតិវិធី និងសំណុំបែបបទ ដែលត្រូវការបំពេញសម្រាប់ការដឹកជញ្ជូន ឆ្លងកាត់ព្រំដែន

២-ធ្វើការបកប្រែជាភាសាអង់គ្លេស នូវរាល់ឯកសារទាំងអស់ដែលប្រើប្រាស់សម្រាប់ចរាចរឆ្លងកាត់ព្រំដែន

៣-សម្របសម្រួលឯកសាររបស់ខ្លួន ទៅតាមឯកសារគំរូរបស់អង្គការសហប្រជាជាតិ សម្រាប់ឯកសារពាណិជ្ជកម្ម

4-ធ្វើឱ្យស៊ីសង្វាក់គ្នា តាមតែអាចធ្វើទៅបាន កូដទំនិញ ផលិតផល និងការបរិយាយទាំងឡាយ ដែលគេនិយមប្រើប្រាស់ជារួម ក្នុងពាណិជ្ជកម្មឆ្លងដែន ដូចដែលបានកំណត់ក្នុងឧបសម្ព័ន្ធទី ៥ ។

5-ពិនិត្យឡើងវិញនូវរាល់ឯកសារ និងនីតិវិធីទាំងអស់ ដែលត្រូវការចាំបាច់ និងមានសារៈសំខាន់សម្រាប់ការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ។

6-លុបបំបាត់ចោលនូវឯកសារ និងការទាមទារជាផ្លូវការទាំងឡាយណា ដែលលើសពីសេចក្តីត្រូវការ

7-ធានាអនុវត្ត តាមគ្រប់រង្វាស់រង្វាល់ SI Units (ប្រព័ន្ធអន្តរជាតិនៃឯកតាពោន់តោន ឬប្រព័ន្ធអន្តរជាតិនៃឯកតាមេទ្រិកម៉ូដឹម (Modem Metric Units) នៅឆ្នាំ ២០០៥

8-ជូនដំណឹងជាមុនទៅភាគីផ្សេងទៀត អំពីតម្រូវការបន្ថែម ឬការផ្លាស់ប្តូរឯកសារ និងនីតិវិធីការណែនាំទាំងឡាយ ដើម្បីផ្តល់ជាសញ្ញាណ និងប្រើប្រាស់ក្នុងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ។

កិច្ចព្រមព្រៀងនេះ ជាកម្មវត្ថុក្នុងការផ្តល់សច្ចាប័ន ឬការទទួលយល់ព្រមចូលពីភាគីចុះកិច្ចសន្យា ។

ត្រូវធានា សម្រួលខ្លឹមសារបទប្បញ្ញត្តិជាតិ ដែលពាក់ព័ន្ធឱ្យមានខ្លឹមសារដូច ឬស្របតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនៅចំណុចណាដែលចាំបាច់ ។ ការដាក់ល័ក្ខខ័ណ្ឌនៅលើកិច្ចព្រមព្រៀង ពុំត្រូវបានគេអនុញ្ញាតឡើយ ។

កិច្ចព្រមព្រៀងនឹងចូលជាធរមាននៅថ្ងៃ ដែលភាគីចុះកិច្ចសន្យាទាំងអស់ បានផ្តល់សច្ចាប័ន ឬការឯកភាពលើកិច្ចព្រមព្រៀង។ ភាគីនីមួយៗអាចព្យួរទុកនូវការអនុវត្តកិច្ចព្រមព្រៀងជាបណ្តោះអាសន្ន ដែលមានឥទ្ធិពលភ្លាមៗ ក្នុងករណីមានការរីករាលអាសន្នជាបន្ទាន់ ដែលប៉ះពាល់ដល់សន្តិសុខជាតិរបស់ខ្លួន និងត្រូវជូនពត៌មានទៅភាគីផ្សេងទៀត អំពីការព្យួរទុក និងអំពីការបញ្ចប់ការព្យួរទុកនេះឱ្យបានឆាប់បំផុតតាមតែអាចធ្វើទៅបាន នៅពេលណាដែលសភាពការណ៍វិលត្រឡប់ទៅស្ថានភាពជាធម្មតាវិញ ។

កិច្ចព្រមព្រៀង ឬក៏សកម្មភាពណាមួយក្នុងកិច្ចព្រមព្រៀងនេះ នឹងមិនមានប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនីមួយៗនៅក្រោមកិច្ចព្រមព្រៀង ឬអនុសញ្ញាអន្តរជាតិផ្សេងទៀតដែលមានស្រាប់ដែលភាគីទាំងនេះ ជាសមាជិកដែរនោះទេ ។

ទំនាស់រវាងភាគី ២ ឬភាគីច្រើននៅលើការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងត្រូវស្រុះស្រួលដោះស្រាយដោយផ្ទាល់ ឬដោយការចរចាតាមគោលការណ៍សន្តិវិធី តាមរយៈគណៈកម្មាធិការរួម ។ ភាគីនីមួយៗ អាចស្នើធ្វើវិសោធនកម្ម កិច្ចព្រមព្រៀងនេះដោយឆ្លងកាត់គណៈកម្មាធិការរួម ។ ការចូលជាធរមាន នៃវិសោធនកម្មលើកិច្ចព្រមព្រៀងនេះត្រូវមានការយល់ព្រមជាឯកច្ឆ័ន្ទ នៃភាគីទាំងអស់ ។

កិច្ចព្រមព្រៀងនេះ អាចប្រកាសបដិសេធដោយភាគីណាមួយ បន្ទាប់ពីការផុតចំនួនកំហេត់ឆ្នាំ គិតចាប់ពីថ្ងៃដែលកិច្ចព្រមព្រៀងចូលជាធរមាន និងត្រូវធ្វើសេចក្តីប្រកាសជូនដំណឹង ផ្ញើរជូនទៅភាគីផ្សេងទៀត ។ ការប្រកាសបដិសេធត្រូវមានប្រសិទ្ធភាពមួយឆ្នាំ បន្ទាប់ពីការធ្វើសេចក្តីជូនដំណឹងរបស់ខ្លួន ។

សេចក្តីដូចបានទូលថ្វាយ និងជម្រាបជូនខាងលើនេះ សូមរដ្ឋសភាមេត្តាពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់នេះដោយអនុគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ១ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

៥

Tril-agee-landtranspt220102 01/21/02 ,

បកប្រែក្រៅផ្លូវការ

កិច្ចព្រមព្រៀងរវាង សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃឡង់ និងសាធារណរដ្ឋសង្គមនិយមវៀតណាម សំរាប់ ការសំរួលនៃការដឹកជញ្ជូនទំនិញ និងប្រជាពលរដ្ឋ ឆ្លងកាត់ព្រំដែន

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ រាជាណាចក្រថៃឡង់ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ហៅកាត់ថា ¨ ភាគីចុះកិច្ចសន្យា ¨ ។

ដោយមានបំណងយ៉ាងសកម្ម ដើម្បីថែរក្សា អភិវឌ្ឍន៍ និងពង្រឹងបន្ថែម ចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងភាគីចុះកិច្ចសន្យា រួមចំណែកយ៉ាងមុតមាំ ដើម្បីជួយអភិវឌ្ឍន៍ នូវទំនាក់ទំនងពាណិជ្ជកម្មរបស់គេ នៅក្នុងក្របខ័ណ្ឌនៃការឆ្លងកាត់គ្នាខាងសេដ្ឋកិច្ច នៅក្នុងអនុតំបន់

ដោយមានឆន្ទៈលើកតំកើង បង្កើនការរួមសហការគ្នា លើវិស័យដឹកជញ្ជូនតាមផ្លូវគោក

ដោយគ្រាន់ចាំបាច់ខាង ការសំរួលពាណិជ្ជទំនិញ និងពលរដ្ឋក្នុងផលប្រយោជន៍រួមគ្នា រវាង ភាគីចុះកិច្ចសន្យា

ដោយទទួលស្គាល់ថា បណ្តាប្រទេសនានានៅក្នុងតំបន់ បានប្រកាន់យកជំហរជាទ្វេភាគី និងជាពហុភាគី ឆ្ពោះទៅរកការរៀបចំកិច្ចសហប្រតិបត្តិការជាមួយគ្នា ដើម្បីសំរួលការដឹកជញ្ជូនផ្លូវគោក

បញ្ជាក់នូវគោលប្រាថ្នាចិត្តរបស់គេ ក្នុងការអភិវឌ្ឍន៍ និងថែរក្សា ប្រព័ន្ធដឹកជញ្ជូន និងគមនាគមន៍មួយ ដែលមានផលប្រយោជន៍ទៅវិញទៅមក រលូន រហ័ស សមហេតុផលត្រឹមត្រូវ និងមានប្រសិទ្ធភាព

ដោយរំលឹកឡើងវិញនូវសេចក្តីសំរេចលេខ 48/11 របស់គណៈកម្មាធិការសេដ្ឋកិច្ច និងសង្គមកិច្ច របស់អង្គការសហប្រជាជាតិ សំរាប់អាស៊ី-ប៉ាស៊ីហ្វិក (ESCAP) ស្តីពីប្រភេទនៃការដឹកជញ្ជូនតាមផ្លូវគោក និងផ្លូវដែក ក្នុងការទំនាក់ទំនងឆ្លងឆ្ពោះទៅរក វិធានការសំរួល និងសេចក្តីណែនាំរបស់កិច្ចប្រជុំលើកទី3 នៃវេទិកាដឹកជញ្ជូនក្នុងតំបន់ ដែលបានប្រព្រឹត្តទៅនៅគុនមិញ ពីថ្ងៃទី 12-13 ធ្នូ ឆ្នាំ 1995 នៅក្រោមកម្មវិធីវិសាលភាពនៃអនុតំបន់ទន្លេមេគង្គ (GMS) ។

បានព្រមព្រៀងគ្នាដូចខាងក្រោម :

ផ្នែកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ ._ គោលបំណង និងកម្មវត្ថុ

គោលបំណងនៃកិច្ចព្រមព្រៀងមានដូចតទៅ:

ក- សំរួលការដឹកជញ្ជូនទំនិញ និងប្រជាពលរដ្ឋឆ្លងកាត់ព្រំដែន រវាង និងក្នុងរង្វង់បណ្តាប្រទេសចុះកិច្ចសន្យា ។

ខ- កាត់បន្ថយ និងធ្វើអោយស៊ីសង្វាក់គ្នាខាងផ្លូវច្បាប់ បទបញ្ញត្តិ នីតិវិធី និងលំនាំលក្ខខ័ណ្ឌនានា ដែលជាប់ទាក់ទងទៅនឹង ការដឹកជញ្ជូនទំនិញ និងប្រជាពលរដ្ឋឆ្លងកាត់ព្រំដែន ។

គ- ជំរុញការដឹកជញ្ជូនពហុរូបភាព

មាត្រា២._ វិសាលភាពនៃការអនុវត្តន៍

ក- កិច្ចព្រមព្រៀងអនុវត្តចំពោះការដឹកជញ្ជូន (ចូល-ចេញ ឬឆ្លងកាត់ទឹកដី នៃភាគីចុះកិច្ចសន្យាណាមួយ) ឆ្លងកាត់ព្រំដែន(រួមមានការដឹកជញ្ជូនតាមរថយន្តមួយគ្រឿង ឬច្រើនគ្រឿង ទាំងការដឹកជញ្ជូនផលក្ខណៈពាណិជ្ជកម្ម

Tri-agee-land transpt220102 01/21/02 *ចុកប្រែក្រៅផ្លូវការ*

ដោយអាជីវករដឹកជញ្ជូនសាធារណៈ ឬផាងគជន ឬមួយជាការដឹកជញ្ជូនផ្ទាល់ខ្លួន ឬសំរាប់ជួល) តាមផ្លូវថ្នល់ (រាប់បញ្ចូលទាំងការឆ្លងកាត់ទន្លេតាមសាឡាងចំលង នៅទីណាដែលពុំមានស្ពានឆ្លង) ទាំងទំនិញ និងពលរដ្ឋ ។

ខ- កិច្ចព្រមព្រៀងមិនអាចអនុវត្តដោយផ្ទាល់ទៅលើការងារពាណិជ្ជកម្ម និងអន្តោប្រវេសន៍ទេ លើកលែងតែមានការថ្លែងបញ្ជាក់ដោយឡែក ។ ហេតុដូច្នេះហើយ កិច្ចព្រមព្រៀងមិនមានប៉ះពាល់ទៅ ដល់សិទ្ធិរបស់ភាគីចុះកិច្ចសន្យាក្នុងការអនុញ្ញាតលើការនាំចូល-នាំចេញ-ការឆ្លងកាត់ នូវទំនិញ និងការចូល-ចេញ-ការឆ្លងកាត់របស់ប្រជាពលរដ្ឋ អោយចូលទៅក្នុងទឹកដីរបស់ខ្លួន ដោយយោងទៅតាមច្បាប់ និងបទបញ្ញត្តិរបស់ពួកគេ ។

មាត្រា៣.. អត្ថន័យនៃពាក្យ ដែលប្រើប្រាស់ក្នុងកិច្ចព្រមព្រៀង

សំរាប់អនុវត្តកិច្ចព្រមព្រៀង អត្ថន័យខាងក្រោម និងត្រូវអនុវត្តទៅលើពាក្យពេចន៍ ដែលមានគំនូសបន្ទាត់ ពីខាងក្រោម ដូចតទៅ :

ក- <u>កិច្ចព្រមព្រៀង</u> : កិច្ចព្រមព្រៀងនេះ រួមជាមួយឧបសម្ព័ន្ធ និងពិធីសារទាំងឡាយ រវាង និងក្នុងរង្វង់ក្របខ័ណ្ឌរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ, ព្រះរាជាណាចក្រថៃ និង សាធារណរដ្ឋសង្គមនិយមវៀតណាម សំរាប់ការសំរួលការដឹកជញ្ជូនទំនិញ និង ពលរដ្ឋឆ្លងកាត់ព្រំដែន ។

ខ- <u>ឧបសម្ព័ន្ធ</u>: អត្ថបទមួយភ្ជាប់ទៅនឹងកិច្ចព្រមព្រៀង ដែលមានលំអិតខាងបច្ចេកទេស ។ ឧបសម្ព័ន្ធមួយ បង្កើតជាចំណែកមួយនៃកិច្ចព្រមព្រៀង និងមានសុពលភាពខាងផ្លូវច្បាប់ស្មើគ្នា ។

គ- <u>ការដឹកជញ្ជូនខាងក្នុង</u> : ជាការដឹកជញ្ជូនផ្ទៃក្នុង រវាងចំណុចពីរ ដែលស្ថិតក្នុងទឹកដីនៃភាគីកិច្ចសន្យាមួយ ហើយដែលសកម្មភាពដឹកជញ្ជូននេះ អនុវត្តដោយអាជីវករដឹកជញ្ជូន នៃភាគីចុះកិច្ចសន្យាដទៃមួយផ្សេងទៀត ។

ឃ- <u>អាជ្ញាធរមានសមត្ថកិច្ច</u> : ភ្នាក់ងារមួយ ឬភ្នាក់ងារទាំងឡាយ ដែលកំណត់ដោយរដ្ឋាភិបាល និង ទទួលខុសត្រូវ ក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ ។

ង- <u>ទំនិញគ្រោះថ្នាក់</u> : ទំនិញទាំងឡាយដែលមានលក្ខណៈវិនិច្ឆ័យ កំណត់ក្នុងឧបសម្ព័ន្ធ១ ។

ច- <u>ចរាចរក្នុងប្រទេស</u> : ការដឹកជញ្ជូនខាងក្នុងដែនដី នៃភាគីចុះកិច្ចសន្យាណាមួយ ។

ឆ- <u>ប្រទេសដើម</u> : <u>សំរាប់ពលរដ្ឋ</u> គឺជាប្រទេសដែលពលរដ្ឋមានទីលំនៅស្នាក់នៅជាធម្មតានៅទីនោះ ។ <u>សំរាប់អាជីវករដឹកជញ្ជូន</u> ជាប្រទេសដែលអាជីវករ បានចុះបញ្ជី និងមានទីស្នាក់ការអចិន្ត្រៃយ៍នៅទីនោះ ។ <u>សំរាប់យានយន្ត</u> ជាប្រទេសដែលយានយន្តបានចុះបញ្ជីនៅទីនោះ ។:

ជ-ប្រទេសសាមី <u>ឬប្រទេសរៀបចំ</u> : ជាប្រទេសដែលនៅទីនោះការដឹកជញ្ជូនត្រូវធ្វើសកម្មភាព ។

ឈ-<u>ប្រទេសគ្មានសមុទ្រ</u> : ជាប្រទេសមួយដែលពុំមានឆ្នេរសមុទ្រ ។

ញ-<u>យានយន្ត</u>: យានដែលមានកំលាំងជំរុញ ឬទាញ ដោយម៉ាស៊ីន ដែលជាធម្មតា ប្រើប្រាស់សំរាប់ដឹកជញ្ជូនពលរដ្ឋ ឬ ទំនិញ តាមផ្លូវគោក ដែលមានប្រភេទកំណត់នៅក្នុងឧបសម្ព័ន្ធទី២ ។

ដ-<u>សេវាដឹកជញ្ជូនពុំមានកំណត់ពេល</u> : គឺជាសេវាដឹកជញ្ជូនមួយ ដែលពុំមែនជា សេវាមានកំណត់ពេលវេលាមួយច្បាស់លាស់។

ឋ-<u>ពលរដ្ឋ</u>: ជាប្រជាពលរដ្ឋ ដែលធ្វើសកម្មអាជីវកម្មដឹកជញ្ជូនផ្សេងៗ និងពលរដ្ឋ ដែលមិនមានជាប់ទាក់ទងក្នុងអាជីវកម្មដឹកជញ្ជូនទាំងនោះ រួមមានអ្នកដំណើរ និង ទេសចរ ។

ឌ-<u>ទំនិញងាយខូចលឿយ</u>: ទំនិញដែលមានកំណត់លក្ខណៈវិនិច្ឆ័យក្នុងឧបសម្ព័ន្ធ៣ ។

ឍ-<u>ពិធីសារ</u>: គឺជាអត្ថបទមួយភ្ជាប់ជាមួយកិច្ចព្រមព្រៀង ដែលមានបញ្ជាក់ពីពេលវេលា ទីតាំង និងកត្តាផ្លាស់ប្តូរផ្សេងៗ ។ ពិធីសារនីមួយៗបង្កើតជាផ្នែកមួយនៃកិច្ចព្រមព្រៀង និងមានសុពលភាពខាងផ្លូវច្បាប់ស្មើៗគ្នា ។

ណ-<u>ការដឹកជញ្ជូនតាមផ្លូវគោក</u> : រួមមានទាំងការឆ្លងកាត់ទន្លេ ដោយសាឡាងចំលង នៅកន្លែងណាដែលពុំមានស្ពាន ។

ត-<u>សេវាដឹកជញ្ជូនមានពេលកំណត់</u>: សេវាដឹកជញ្ជូន នៅលើផ្លូវកំណត់មួយ ដោយអនុលោមទៅតាមតារាង ផ្លូវដឹកជញ្ជូន

Tri-ages-landtransp t220102 01/21/02 ចក់ប្រែក្រៅផ្លូវការ

កំណាត់មួយ ដែលមានបញ្ជាក់ជាស្រេចអំពីកន្លែងកំណត់អោយឈប់នានា និងដែលមានការផាក់តំលៃសំរាប់ យកឈ្នួល ហើយដែលអាចប្រើប្រាស់បានគ្រប់គ្នា លើគោលការណ៍ អ្នកមកដល់មុនបំរើមុន រឺក៏ទិញសំបុត្រទុកជាមុន ។

ទ-ប្រទេសទី៣: ប្រទេសមួយដែលពុំមែនជាភាគីចុះកិច្ចសន្យាណាមួយ នៃកិច្ចព្រមព្រៀងនេះ ។

ធ-អាជីវករដឹកជញ្ជូន : បុគ្គល ឬនីតិបុគ្គល ជាលក្ខណៈឯកជន ឬជាសាធារណៈ ដែលជាអ្នកធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ ឬក៏អ្នកដំណើរតាមផ្លូវគោក សំរាប់យកកម្រៃ ឬកំរៃ ។

ន-ការដឹកជញ្ជូនផ្ទាល់ខ្លួន: ការធ្វើអាជីវកម្មដឹកជញ្ជូនមួយ ដែលជាសកម្មភាពបន្ទាប់បន្សំ របស់សហគ្រាសមួយ ដើម្បីដឹកជញ្ជូន បុគ្គលិក កម្មករ ឬទំនិញរបស់គេ ក្នុងរបភាពពាណិជ្ជកម្មរបស់គេ តាមរថយន្តទាំងឡាយ ដែលជាកម្មសិទ្ធរបស់សហគ្រាស ផ្ទាល់ និងបើកបរដោយបុគ្គលិករបស់សហគ្រាស ។

ប-ប្រទេសឆ្លងកាត់: ប្រទេសមួយដែលការដឹកជញ្ជូនឆ្លងកាត់ ត្រូវធ្វើឡើងកាត់តាមដែនដីនៃប្រទេសនោះ ។

ផ- ការដឹកជញ្ជូនឆ្លងកាត់: ការដឹកជញ្ជូនទំនិញឆ្លងកាត់តាមទឹកដីនៃភាគីចុះកិច្ចសន្យាមួយ នៅពេលដែលការឆ្លងកាត់ តាមទឹកដីនេះគ្រាន់តែជាផ្នែកមួយ(កំណាត់ផ្លូវមួយ) នៃដំណើរមួយពេញ ដែលមានចំណុចចាប់ផ្តើម និងចំណុចបញ្ចប់ ស្ថិតនៅក្រៅព្រំដែននៃភាគីចុះកិច្ចសន្យាមួយ ដែលចរាចរដឹកជញ្ជូន ឆ្លងកាត់ទឹកដីរបស់គេ ។

ព- យាន: រាល់មធ្យោបាយ ដឹកជញ្ជូនតាមផ្លូវថ្នល់ ។

ផ្នែកទី២

ការសំរួលបែបបទឆ្លងកាត់ព្រំដែន

មាត្រា៤... ការសំរួលបែបបទឆ្លងកាត់ព្រំដែន :

ភាគីចុះកិច្ចសន្យា ត្រូវឯកភាពគ្នាសម្រេចនូវវិធានការដូចខាងក្រោម ដើម្បីកាត់បន្ថយនិង ធ្វើអោយបានឆាប់រហ័ស នូវបែបបទតាមព្រំដែន ដោយអនុលោមទៅតាមឧបសម្ព័ន្ធទី៤ :

ក- ការត្រួតពិនិត្យរួមគ្នាតែមួយ: អធិការកិច្ច និងការត្រួតពិនិត្យផ្សេងៗទៅលើពលរដ្ឋ (លិខិតឆ្លងដែន ទិដ្ឋាការ , បណ្ណបើកបរ, ការប្តូរប្រាក់, គយរង្វាស់, សុខភាព និងការពិនិត្យរោគរាតត្បាត) ទៅលើយានយន្ត: (ការចុះបញ្ជី លក្ខណៈបច្ចេកទេសយានយន្ត ការធានារ៉ាប់រង) និងទំនិញ(គយផ្ទាំង គុណភាព ភូតគាមអនាម័យ, ការការពារដំណាំរុក្ខជាតិ បសុពេទ្យ)ត្រូវអនុវត្តរួមគ្នា និង ព្រមពេលជាមួយគ្នា ដោយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធរៀងៗខ្លួន (នាយកដ្ឋានគយ ប៉ូលីសអន្តោប្រវេសន៍ មន្ត្រីពាណិជ្ជកម្ម មន្ត្រីកសិកម្ម មន្ត្រីសុខាភិបាល) ។

ខ- ការត្រួតពិនិត្យតែមួយលើក: មន្ត្រីនៃប្រទេសជាប់ដែន ត្រូវជួយគ្នាពីមួយទៅមួយ និងទៅវិញទៅមក តាមលទ្ធភាព ដែលអាច ធ្វើទៅបាន ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។អាជ្ញាធរជាតិដែលស្ថិតនៅជាប់គ្នាទាំងពីរ នឹងត្រូវអនុវត្ត ការត្រួតពិនិត្យរួមគ្នា និងព្រមពេលជាមួយគ្នា ។ នៅកន្លែងណាដែលស្ថានភាពភូមិសាស្ត្រជាមូលដ្ឋាន ពុំអាចអនុញ្ញាត អោយសាងសង់នូវប៉ុស្តិ៍ត្រួតពិនិត្យដែលស្ថិតនៅជាប់រួមជាមួយគ្នានៅតាមព្រំដែនបាន មន្ត្រីត្រួតពិនិត្យនៃភាគីកិច្ចសន្យាមួយ ត្រូវបានអនុញ្ញាតធ្វើសកម្មភាពការងារត្រួតពិនិត្យ របស់ខ្លួននៅលើទឹកដីនៃភាគីចុះកិច្ចសន្យាមួយផ្សេងទៀត ។

គ- ការសំរបសំរួលពេលម៉ោងធ្វើការងារ: ភាគីចុះកិច្ចសន្យា ត្រូវសំរបសំរួលពេលម៉ោងធ្វើការងារ របស់អាជ្ញាធរ ត្រួតពិនិត្យការឆ្លងកាត់ព្រំដែន ដែលនៅជាប់គ្នា ។

ឃ- ការប្តូរគ្នាជាមុន នូវព័ត៌មាន និងការជំរះបែបបទ: ភាគីចុះកិច្ចសន្យានឹងធ្វើការរួមគ្នា ក្នុងការអនុញ្ញាត អោយមានការផ្លាស់ប្តូរគ្នាជាមុន នូវព័ត៌មាន និងការជំរះបែបបទ នៃទំនិញនិងពលរដ្ឋ ។

ផ្នែកទី៣

Tri-agee-landtransp:220102 01/21/02

បកប្រែក្រៅផ្លូវការ

ការដឹកជញ្ជូនប្រជាពលរដ្ឋឆ្លងកាត់ព្រំដែន

មាត្រា៥.. ទិដ្ឋាការ

ក- <u>ចំពោះបុគ្គលដែលធ្វើសកម្មភាពបំរើអោយអាជីវកម្មដឹកជញ្ជូន</u> :

ភាគីចុះកិច្ចសន្យាទទួលរ៉ាប់រង ក្នុងការផ្តល់ទិដ្ឋាការជូនទៅជនជាតិទាំងឡាយនៃភាគីចុះកិច្ចសន្យាដទៃផ្សេងទៀត ដែលធ្វើអាជីវកម្ម ដឹកជញ្ជូន ហើយដែលស្របទៅនឹងតំរូវការ នៃអ្នកស្នើសុំទិដ្ឋាការចូលច្រើនដង ទិដ្ឋាការឆ្លងកាត់និងទិដ្ឋាការចេញ សំរាប់រយៈពេលវែង ។

ខ- <u>សំរាប់ពលរដ្ឋដែលមិនធ្វើសកម្មភាពបំរើអោយអាជីវកម្មដឹកជញ្ជូន</u> :

លក្ខខ័ណ្ឌ និងបែបបទនៃការចេញទិដ្ឋាការ និងត្រូវបរិយាយយ៉ាងល្អិតល្អន់ នៅឧបសម្ព័ន្ធ ទី5 ។

មាត្រា៦ .. ការដឹកជញ្ជូនពលរដ្ឋ

សកម្មភាពដឹកជញ្ជូនពលរដ្ឋឆ្លងកាត់ព្រំដែន(ដូចជារថយន្ត ផ្លូវដឹកជញ្ជូន តំលៃសំបុត្រ) នឹងត្រូវបញ្ញត្តិ នៅក្នុងឧបសម្ព័ន្ធទី 5 និងពិធីសារទី1 ។

ផ្នែកទី4:
ការដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែន

មាត្រា ៧ .. ការលើកលែង ចេញពីការត្រួតពិនិត្យជាក់ស្តែងរបស់គយ ការតំកល់ប្រាក់ធានា និងការអមបំរើ ។

(ក) ភាគីចុះកិច្ចសន្យា ត្រូវធានាក្នុងការលើកលែងចំពោះទំនិញ ឆ្លងកាត់ជាអន្តរជាតិចេញពី :

1- ការត្រួតពិនិត្យជាក់ស្តែងរបស់គយជាប្រចាំ នៅព្រំដែន

2- ការអមទំនិញដោយគយ នៅក្នុងទឹកដីរបស់ខ្លួន

3- ការតំកល់ប្រាក់កក់ក្នុងចំនួនណាមួយ សំរាប់ជាការធានាការបង់ពន្ធគយ ។

(ខ) ដើម្បីអនុវត្តដូចនេះ ភាគីចុះកិច្ចសន្យា ត្រូវរៀបចំឡើងនូវរបបបំរះបែបបទគយ ខាងក្នុងប្រទេស និងឆ្លងកាត់ ដូចមានបញ្ជាក់ក្នុងឧបសម្ព័ន្ធទី 6។

មាត្រា ៨ .. ចរាចរឆ្លងកាត់

(ក) ភាគីចុះកិច្ចសន្យាត្រូវផ្តល់អោយដោយសេរី នូវការឆ្លងកាត់ តាមដែនដីរបស់ខ្លួន សំរាប់ការដឹកជញ្ជូនឆ្លងកាត់ ឆ្ពោះទៅ ឬត្រឡប់មកពីទឹកដីនៃភាគីចុះកិច្ចសន្យាផ្សេងទៀត ។

(ខ) ការដឹកជញ្ជូនឆ្លងកាត់ នឹងត្រូវលើកលែងមិនអោយមានជាប់ពន្ធគយ និងពន្ធដារផ្សេងៗទៀតឡើយ ។

(គ) ការចំណាយនានា ដែលពាក់ព័ន្ធទៅនឹងការដឹកជញ្ជូនឆ្លងកាត់ ក្រៅពីពន្ធគយ និងអាករផ្សេងៗ នឹងត្រូវបង់ថ្លៃ ជាបណ្តើរៗ ជា2 ជំហាន :

- <u>ជំហានទី1</u> : ការចំណាយពាក់ព័ន្ធទៅនឹងការដឹកជញ្ជូនឆ្លងកាត់ ក្រៅអំពីពន្ធគយ និងអាករផ្សេងៗ ត្រូវបង់ថ្លៃ ដូចជាការកំណត់ក្នុងពិធីសារទី2 ។
- <u>ជំហានទី2</u> : ការបង់ថ្លៃធានាលើចរាចរដឹកជញ្ជូនឆ្លងកាត់ គឺមានត្រឹមតែជាការចំណាយដែលពាក់ព័ន្ធប៉ុណ្ណោះ ។

មាត្រា ៩ .. ការត្រួតពិនិត្យភូតគាមអនាម័យ និងបសុពេទ្យ

ភាគីចុះកិច្ចសន្យានឹងត្រូវគោរពតាម កិច្ចព្រមព្រៀងអន្តរជាតិ ដែលពាក់ព័ន្ធទៅនឹងបទបញ្ញត្តិ នៃអង្គការសុខភាពពិភពលោក អង្គការម្ហូបអាហារ និងកសិកម្ម និងការិយាល័យអន្តរជាតិនៃរោគរាតត្បាតរបស់សត្វ ក្នុងការអនុវត្ត ការត្រួតពិនិត្យទំនិញឆ្លងកាត់ព្រំដែន ។

មាត្រា ១០ .- របបពិសេស សំរាប់ការដឹកជញ្ជូន ទំនិញមានលក្ខណៈវិនិច្ឆ័យពិសេស

(ក) កិច្ចព្រមព្រៀង មិនអនុវត្តទៅលើការដឹកជញ្ជូន ទំនិញគ្រោះថ្នាក់ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ 1

(ខ) ការដឹកជញ្ជូនទំនិញងាយខូចគុណភាព ដូចបានកំណត់ក្នុងពិធីសារទី3 នឹងត្រូវផ្តល់ជារបបអាទិភាពមួយ សំរាប់រៀបចំបំពេញ និងដំណើរបែបបទឆ្លងកាត់ព្រំដែន ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី3 ដើម្បីអោយទំនិញទាំងនេះ ចៀសផុតពីការពន្យាពេលយឺតយ៉ាវពុំសមស្របបាន ។

ជំពូកទី ៥ :

លក្ខខណ្ឌ សំរាប់ការអនុញ្ញាតអោយយកចូល នូវយានយន្តដឹកជញ្ជូន

មាត្រា ១១ .- ការអនុញ្ញាតអោយយកចូលយានយន្តដឹកជញ្ជូន ទៅក្នុងភាគីចុះកិច្ចសន្យាផ្សេងទៀត

យោងតាមលក្ខខណ្ឌទាំងឡាយ ដែលមានចែងក្នុងជំពូកនេះ ភាគីចុះកិច្ចសន្យា ត្រូវអនុញ្ញាតអោយចូលមកក្នុងទឹកដីរបស់ខ្លួន ទាំងរថយន្តដឹកទំនិញ រឺដឹកអ្នកដំណើរ (រីក៏ធ្វើពាណិជ្ជកម្មយកចំណេញ រឺរបស់ផ្ទាល់ខ្លួន រឺឯកជន) ដែលចុះបញ្ជីដោយភាគី ចុះកិច្ចសន្យាដទៃផ្សេងទៀត ។

មាត្រា ១២ .- ការចុះបញ្ជី

(ក) យានយន្តទាំងឡាយ ដែលធ្វើចរាចរឆ្លងកាត់ព្រំដែន ត្រូវចុះបញ្ជីនៅក្នុងប្រទេសដើមរបស់ខ្លួន និងស្របទៅតាមបទបញ្ញត្តិ ដែលមាននៅក្នុងឧបសម្ព័ន្ធ ទី2 ។

(ខ) យានយន្តទាំងឡាយត្រូវមានបញ្ជាក់សញ្ញាសំគាល់ (សញ្ញាពាណិជ្ជកម្មនៃរោងចក្រផលិត លេខតួ និងលេខម៉ាស៊ីន) មានវិញ្ញាបនប័ត្រចុះបញ្ជី, មានបំពាក់លេខចុះបញ្ជីនៅលើផ្លាកលេខមួយ ពាក់នៅខាងក្រោយ និងខាងមុខ, និងបំពាក់នូវសញ្ញាសំគាល់ប្រទេសដែលយានយន្តបានចុះបញ្ជី ។

មាត្រា ១៣ .- លក្ខខណ្ឌបច្ចេកទេស

យានយន្ត និងកុងទីណឺ ដែលធ្វើដំណើរឆ្លងទៅទឹកដីនៃភាគីចុះកិច្ចសន្យាផ្សេងទៀត ត្រូវបំពាក់ គ្រប់គ្រាន់នូវសំភារៈសុវត្ថិភាព និងមានការតការបញ្ចេញផ្សែងអោយត្រឹមត្រូវតាមស្តង់ដារ ដែលធរមាននៅក្នុងប្រទេសដើម របស់គេ ។ យានយន្តដែលធ្វើដំណើរទៅកាន់ទឹកដីនៃភាគីចុះកិច្ចសន្យាដទៃ ត្រូវតែគោរពតាមស្តង់ដារបច្ចេកទេស នៃប្រទេសសាមីឬប្រទេសរៀបចំ ដែលទាក់ទងទៅនឹងទំងន់សរុប បន្ទុកភ្លៅ និងទំហំខ្នាតនៃយាន ។

មាត្រា ១៤ .- ការទទួលស្គាល់ វិញ្ញាបនប័ត្រត្រួតពិនិត្យបច្ចេកទេសយានយន្ត

(ក) យានយន្តដែលធ្វើដំណើរឆ្លងទៅកាន់ទឹកដីនៃភាគីចុះកិច្ចសន្យាដទៃផ្សេងទៀត ត្រូវមានដំណើរការល្អខាងបច្ចេកទេស

(ខ) ប្រទេសដើម ជាអ្នកទទួលបន្ទុកក្នុងការត្រួតពិនិត្យលក្ខណៈបច្ចេកទេស របស់យានយន្ត ដែលចុះបញ្ជីនៅក្នុងទឹកដីរបស់ខ្លួន ។ឈរលើមូលដ្ឋាននេះ ប្រទេសដើមត្រូវចេញវិញ្ញាបនប័ត្រ ត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត។

(គ) ភាគីចុះកិច្ចសន្យាដទៃទៀត ត្រូវទទួលស្គាល់នូវវិញ្ញាបនបត្រនេះ ។

មាត្រា ១៥ .. បទបញ្ញត្តិ និងផ្លាកសញ្ញាចរាចរណ៍តាមផ្លូវថ្នល់

ភាគីចុះកិច្ចសន្យា ធានា អនុម័តិជាជំហានៗយកផ្លាកសញ្ញា និងបទបញ្ញត្តិចរាចរផ្លូវគោក និងស្តង់ដារ ដែលកំណត់ក្នុងឧបសម្ព័ន្ធទី 7 ។

មាត្រា ១៦ .. កាតព្វកិច្ចធានារ៉ាប់រងក្នុងការទទួលខុសត្រូវរបស់យានយន្ត ទៅលើភាគីទី3 :

រថយន្តដែលធ្វើដំណើរឆ្លងទៅកាន់ដែនដីនៃភាគីចុះកិច្ចសន្យាផ្សេងទៀត ត្រូវអនុវត្តទៅតាមកាតព្វកិច្ចធានារ៉ាប់រងក្នុងការទទួលខុសត្រូវរបស់យានយន្ត ទៅលើភាគីទី3 ដែលប្រទេសសាមីទាមទារអោយមានជាដាច់ខាត។

មាត្រា ១៧ .. ប័ណ្ណបើកបរ

ភាគីចុះកិច្ចសន្យា ត្រូវទទួលស្គាល់ប័ណ្ណបើកបរ ដែលចេញអោយដោយភាគីចុះកិច្ចសន្យាផ្សេងទៀត ស្របទៅតាមកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ ប័ណ្ណបើកបរក្នុងស្រុក ចេញដោយបណ្តាប្រទេសអាស៊ាន ដែលបានចុះហត្ថលេខានៅគូឡាឡាំពួរ ថ្ងៃទី 9 កក្កដា 1985 ។

មាត្រា ១៨ .. ការនាំចូលយានយន្តជាបណ្តោះអាសន្ន

ភាគីចុះកិច្ចសន្យា ត្រូវផ្តល់អោយនូវការយកចូលជាបណ្តោះអាសន្ន នូវរថយន្ត(និងប្រេងឥន្ធនៈ ដែលមានក្នុងធុងប្រេងផ្គត់ផ្គង់របស់វា, ប្រេងរំអិល , សំភារៈសំរាប់ជួសជុល និងគ្រឿងបន្លាស់ ទៅតាមចំនួនមួយដ៏សមរម្យ) ដែលបានចុះបញ្ជីនៅដែនដីភាគីចុះកិច្ចសន្យាដទៃទៀត ដោយពុំចាំបាច់បង់ពន្ធគយ និងពន្ធនាំចូល ដោយពុំមានការតំកល់ទុកប្រាក់សំរាប់ធានាក្នុងការបង់ពន្ធគយ និងចេញចូលដោយសេរី រួចពីបំរាម និងល័ក្ខខ័ណ្ឌតឹងរឹងនានា ដោយសមស្របសំរាប់ការនាំចេញជាថ្មីនិងសមស្របទៅតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងឧបសម្ព័ន្ធទី 8 ។

ផ្នែកទី ៦ :

ការផ្លាស់ប្តូរសិទ្ធក្នុងការធ្វើចរាចរខាងពាណិជ្ជកម្ម

មាត្រា ១៩ .. សិទ្ធិនៃការធ្វើចរាចរ

សិទ្ធិនៃការធ្វើចរាចរ នឹងត្រូវធ្វើឡើងជាបន្តបន្ទាប់ ជា 02 ជំហានៈ

ជំហានទី 1 : ស្របទៅតាមល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងផ្នែកនេះ អាជីវករដឹកជញ្ជូន ដែលបង្កើតឡើង នៅក្នុងភាគីចុះកិច្ចសន្យាមួយ អាចធានាអោយមានការដឹកជញ្ជូន ដូចខាងក្រោម :

(ក) ការដឹកជញ្ជូនឆ្លងកាត់ កាត់តាមទឹកដីភាគីចុះកិច្ចសន្យាដទៃទៀត

(ខ) ឆ្លងព្រំដែន ចូលទៅក្នុងទឹកដីភាគីចុះកិច្ចសន្យាដទៃទៀត

(គ) ឆ្លងព្រំដែន ចេញពីទឹកដីភាគីចុះកិច្ចសន្យាដទៃទៀត

ជំហានទី2 : អាជីវករដឹកជញ្ជូនដែលបានបង្កើតឡើង នៅក្នុងភាគីចុះកិច្ចសន្យាមួយ អនុលោមតាម កំលាំងសេដ្ឋកិច្ចទីផ្សារសេរី អាចទទួលខុសត្រូវក្នុងការធ្វើអាជីវកម្មដឹកជញ្ជូន ចូលទៅក្នុង-ចេញពី ឬក៏ឆ្លងកាត់ ទឹកដីនៃភាគីចុះកិច្ចសន្យាដទៃទៀត។ ប៉ុន្តែការដឹកជញ្ជូនផ្ទៃក្នុង អាចប្រព្រឹត្តទៅបាន លុះត្រាតែមានការអនុញ្ញាតពិសេសណាមួយ ពីប្រទេសសាមី ។

មាត្រា ២០ .. ការកំណត់ផ្លូវ និងចំណុចនានា សំរាប់ការចូល និងការចេញ

ពិធីសារទី1 បានកំណត់នូវផ្លូវដឹកជញ្ជូនដែលអាចអនុញ្ញាត អោយធ្វើការដឹកជញ្ជូន និងចំនុចចេញ-ចូល សំរាប់ការដឹកជញ្ជូនទំនិញ និងអ្នកដំណើរ ឆ្លងកាត់ព្រំដែន ។

មាត្រា ២៥ .. អាជ្ញាប័ណ្ណសំរាប់អាជីវករដឹកជញ្ជូន (ការអនុញ្ញាតអោយធ្វើអាជីវកម្មដឹកជញ្ជូន)

(ក) អាជីវករដឹកជញ្ជូន ត្រូវមានអាជ្ញាប័ណ្ណសំរាប់ការធ្វើអាជីវកម្មដឹកជញ្ជូនឆ្លងកាត់ ដែលចេញអោយដោយប្រទេសដើមរបស់ខ្លួន ស្របទៅតាមលក្ខណៈវិនិច្ឆ័យ ដែលកំណត់ក្នុងឧបសម្ព័ន្ធទី ៩។

(ខ) អាជ្ញាប័ណ្ណអាជីវកម្ម មិនត្រូវបានគេលក់ រឺផ្ទេរ ដោយនិតិបុគ្គល ដែលគេបានផ្តល់អាជ្ញាប័ណ្ណទៅអោយនោះទេ ។ ។

(គ) ប្រទេសសាមី ត្រូវទទួលស្គាល់អាជ្ញាប័ណ្ណអាជីវកម្ម ដែលចេញអោយដោយប្រទេសដើម ។

មាត្រា ២៦ .. ការចូលទៅក្នុងទីផ្សារ

(ក) អាជីវករដឹកជញ្ជូនណាមួយ ដែលបានទទួលអាជ្ញាប័ណ្ណយ៉ាងត្រឹមត្រូវ សំរាប់ធ្វើអាជីវកម្មដឹកជញ្ជូនឆ្លងកាត់ព្រំដែន នៅឯប្រទេសដើមរបស់ខ្លួន ស្របទៅតាមលក្ខណៈវិនិច្ឆ័យដែលកំណត់ក្នុងឧបសម្ព័ន្ធទី១ នឹងត្រូវទទួលសិទ្ធធ្វើអាជីវកម្មដឹកជញ្ជូនឆ្លងកាត់ព្រំដែន តាមបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ។

(ខ) ប្រទេសសាមី ត្រូវជួយផ្តល់ការអនុញ្ញាតទៅអាជីវករដឹកជញ្ជូន ដែលធ្វើការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដើម្បីបង្កើតការិយាល័យតំណាង ក្នុងគោលបំណងសំរួល ការធ្វើអាជីវកម្មដឹកជញ្ជូនរបស់ខ្លួន ។

មាត្រា ២៧ .. ទីផ្សារសេរី សំរាប់សេវាកម្មដឹកជញ្ជូន

ប្រតិបត្តិការដឹកជញ្ជូន ត្រូវបានអនុញ្ញាតិជាបន្តបន្ទាប់ ជា 02ជំហាន :

ជំហានទី1 : យានយន្តទាំងឡាយ ដែលប្រកបអាជីវកម្ម អនុលោមទៅតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ ត្រូវកំណត់នៅក្នុងពិធីសារ ទី3 នៃកិច្ចព្រមព្រៀង ។ បរិមាណដឹកជញ្ជូនអាចត្រូវគេកំណត់ឡើងក្នុងពិធីសារទី3។ រយៈពេលនៃការអនុវត្ត ជំហានទី ១ នឹងត្រូវគេកំណត់ក្នុងពិធីសារទី៣ ។ គណៈកម្មាធិការជាតិសំរាប់សំរួលការដឹកជញ្ជូន នៃភាគីចុះកិច្ចសន្យានីមួយៗ ដូចមានបញ្ជាក់ក្នុងមាត្រាទី28 ត្រូវប្តូរគ្នា និងចេញអោយនូវបរិមាណដែលអនុញ្ញាតិ ហើយដែលមានការព្រមព្រៀងគ្នារៀងរាល់ឆ្នាំ ។

ជំហានទី2 : បរិមាណ និងសមត្ថភាពនៃការធ្វើអាជីវកម្មដឹកជញ្ជូនស្របតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ នឹងមិនត្រូវអោយមានការតឹងរឹង ជាជាងខ្លឹមសារដែលមានចែងក្នុងកិច្ចព្រមព្រៀងឡើយ ។

មាត្រា ២៨ .. ថ្លៃឈ្នួល និងល័ក្ខខ័ណ្ឌនៃការដឹកជញ្ជូន

(ក) <u>ល័ក្ខខ័ណ្ឌនៃការដឹកជញ្ជូន</u> : ល័ក្ខខ័ណ្ឌនៃការដឹកជញ្ជូន នឹងត្រូវរៀបចំទៅតាមបទបញ្ញត្តិ ដែលកំណត់នៅក្នុងឧបសម្ព័ន្ធទី 10។

(ខ) <u>ថ្លៃឈ្នួល</u> : ការកំណត់តំលៃ សំរាប់ការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ត្រូវអនុវត្តដោយសេរី និងតាមកំលាំងទីផ្សារ ប៉ុន្តែត្រូវដាក់កំរិតក្នុងការប្រមូលផ្តុំសហគ្រាស និងមានការពិនិត្យពិច័យ ពីគណៈកម្មការរួម ដើម្បីចៀសវាងការដាក់ថ្លៃឈ្នួលខ្ពស់ខ្លាំងពេក រឺទាបខ្លាំងពេក ។

ជំពូកទី ៧ : ហេដ្ឋារចនាសម្ព័ន្ធ

មាត្រា ២៩ .. ស្តង់ដារគំនូសប្លង់ នៃផ្លូវ និងស្ពាន

(ក) ការស្ថាបនា ឬការស្ថាបនាជាថ្មីឡើងវិញ នូវផ្លូវថ្នល់(គិតទាំងស្ពាន) ដែលតភ្ជាប់ប្រទេសទាំងឡាយ និងដែលបង្ហាញនៅក្នុងពិធីសារទី1 ត្រូវធ្វើទៅតាមក្របខ័ណ្ឌនៃកម្មវិធីសាធារណការរបស់ជាតិឬក៏ទៅតាមការផ្តល់ប៉េវិកាជាអន្តរជាតិ ។

(ខ) ការស្ថាបនា រឺការស្ថាបនាឡើងវិញ នៃផ្លូវថ្នល់ដែលបានឯកភាពគ្នា (គឺតទាំងស្ពាន) នឹងត្រូវធ្វើឡើង ដោយអនុលោម ទៅតាមលក្ខណៈអប្បរមា ដែលបានកំណត់ក្នុងឧបសម្ព័ន្ធទី 11 ទៅតាមកំរិត ដែលគេបានអនុញ្ញាតិ អោយស្រប ទៅតាម ប្រភពថវិកាដែលមាន ។

(គ) ភាគីចុះកិច្ចសន្យា នឹងធានាថាផ្លូវថ្នល់ដែលបានឯកភាពគ្នា ត្រូវមានសុវត្ថិភាព សន្តិសុខ និងស្ថិតក្នុងលក្ខខ័ណ្ឌល្អ ។ ភាគីចុះកិច្ចសន្យាទាំងអស់ ទទួលរ៉ាប់រងក្នុងការអនុវត្តន៍ ការថ្នួសជុលនានាដែលចាំបាច់ ។

មាត្រា ២៦ .- ផ្លាកសញ្ញា និងភ្លើងសញ្ញានៃផ្លូវថ្នល់

ភាគីចុះកិច្ចសន្យាទទួលរ៉ាប់រង ក្នុងជំហានបន្តបន្ទាប់គ្នា ក្នុងការដាក់ផ្លាកសញ្ញា និងភ្លើងសញ្ញាទាំងឡាយ នៅលើដែនដីរបស់គេ ស្របទៅតាមស្តង់ដារ ដែលបានកំណត់ក្នុងឧបសម្ព័ន្ធទី 7 ។

មាត្រា ២៧ .- បច្ចេកទេសសំរួលការឆ្លងកាត់ព្រំដែន

ភាគីចុះកិច្ចសន្យា ត្រូវទទួលរ៉ាប់រង ក្នុងការស្ថាបនា ឬធ្វើអោយប្រសើរឡើង នូវហេដ្ឋារចនាសម្ព័ន្ធដែលត្រូវការ នៅចំណុចឆ្លងកាត់ព្រំដែន និងក្នុងការរៀបចំចាត់តាំងមន្ត្រីរបស់ខ្លួន អោយបំរើការនៅទីនោះ ដើម្បីធានាការបំពេញបែបបទឆ្លងកាត់ព្រំដែន អោយបានឆាប់រហ័ស និងមានប្រសិទ្ធភាព ដូចមានចែងក្នុងឧបសម្ព័ន្ធទី12 ។

ផ្នែកទី ៨ :
ក្របខ័ណ្ឌនៃការរៀបចំស្ថាប័ន

មាត្រា ២៨ .- គណៈកម្មាធិការជាតិសំរបសំរួលការដឹកជញ្ជូន

ភាគីចុះកិច្ចសន្យា និងបង្កើតឡើងរៀងៗខ្លួន នូវគណៈកម្មាធិការជាតិអចិន្ត្រៃយ៍សំរួលការដឹកជញ្ជូន ដែលត្រូវដឹកនាំដោយរដ្ឋមន្ត្រី រឺអនុរដ្ឋមន្ត្រីមួយរូប រឺមន្ត្រីដែលមានឋានៈស្មើ ។ គណៈកម្មាធិការនេះនឹងត្រូវមានតំណាងគ្រប់រឹដ្ឋតទាំងអស់របស់ក្រសួងស្ថាប័ន ដែលជាប់ពាក់ព័ន្ធក្នុងការអនុវត្តកិច្ចព្រមព្រៀង អោយចូលរួមជាសមាជិក។

មាត្រា ២៩ .- គណៈកម្មាធិការរួម

(ក) តំណាងទាំងឡាយ នៃគណៈកម្មាធិការជាតិសំរួលការដឹកជញ្ជូន នឹងរួមគ្នាបង្កើតឡើង គណៈកម្មាធិការរួមមួយ ។

(ខ) គណៈកម្មាធិការរួមនេះ នឹងតាមដានត្រួតពិនិត្យ និងវាយតំលៃ នូវការប្រព្រឹត្តទៅនៃកិច្ចព្រមព្រៀង ។ គណៈកម្មាធិការនេះ នឹងប្រើប្រាស់ជាវេទិកា សំរាប់ជជែកពិភាក្សា និងដោះស្រាយទំនាស់តាមគោលការណ៍សន្តិវិធី និងជាវេទិកាដែលអាចផ្តល់តំបូន្មាន ទៅកាន់ភាគីចុះកិច្ចសន្យា ព្រមទាំងរៀបចំនូវសំណើធ្វើវិសោធនកម្មកិច្ចព្រមព្រៀង ។

ផ្នែកទី ៩ :
បទបញ្ញត្តិផ្សេងៗ

មាត្រា ៣០ .- ការគោរព និងអនុវត្តតាមច្បាប់ និងបទបញ្ញត្តិរបស់ជាតិ

(ក) ប្រជាពលរដ្ឋ អាជីវករដឹកជញ្ជូន និងរថយន្ត ត្រូវអនុវត្តទៅតាមច្បាប់ និងបទបញ្ញត្តិទាំងឡាយ ដែលនៅជាធរមានក្នុងទឹកដីនៃប្រទេសសាមី ។

Tni-agee-landtransp220102 01/21/02

(ខ) ការអនុវត្តនៃច្បាប់ និងបទបញ្ញត្តិជាមូលដ្ឋាន គឺជាសមត្ថកិច្ចតែមួយគត់ របស់អាជ្ញាធរប្រទេសជាសាមី នៅពេលដែលមានការរំលោភច្បាប់ នៅក្នុងដែនដីនៃប្រទេសរបស់ខ្លួន។

(គ) ប្រទេសជាសាមី អាចបដិសេធជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍នូវការចូលទៅក្នុងដែនដីរបស់ខ្លួន ចំពោះជនណាមួយ អ្នកបើកបរណាមួយ អាជីវករដឹកជញ្ជូនណាមួយ ឬក៏រថយន្តមួយ ដែលបានរំលោភ បទបញ្ញត្តិនៃកិច្ចព្រមព្រៀង ឬក៏ច្បាប់ និងបទបញ្ញត្តិជាតិរបស់ប្រទេសខ្លួន ។

មាត្រា ៣១ .- តម្លាភាពនៃច្បាប់ បទបញ្ញត្តិ និងស្ថានភាពនៃបែបបទនីតិវិធី

ភាគីចុះកិច្ចសន្យា ធានាបង្កើតអោយមានសៀវភៅកំរងច្បាប់ជាតិ បទបញ្ញត្តិ នីតិវិធី និងពត៌មានបច្ចេកទេស អោយទូលំទូលាយជាភាសាអង់គ្លេស អំពីការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ដូចមានចែងក្នុងកិច្ចព្រមព្រៀង ។

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូន លោក ABI SINAN ALASADI សប្បុរសជន ជនជាតិគុយវ៉ែត ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន អស់ចំនួន ១១.៤៦៦ ដុល្លារ សំរាប់ជួយកសាងវិហារឥស្លាម នៅភូមិសំរោង ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ... ឆ្នាំ ២០០៦

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ...៧០...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយជួសជុលព្រះវិហារ ធ្វើខ្លោងទ្វារ របង ប្រាង្គ បន្ទប់ទឹក បង្គន់អនាម័យ និងសមិទ្ធផលមួយចំនួនទៀត នៅ *វត្តហ្លួងស៊ីសុវត្ថិរតនារាម* និង *វត្តកោះកែវល័ង្ការាម* ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម :-

១-លោក **ចៅឡាយ គុយ** សប្បុរសជននៅសហរដ្ឋអាមេរិក ថវិកាចំនួន ២១.២២៣.៥០ ដុល្លារ

២-លោកស្រី **ជា សាន់** សប្បុរសជននៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១៩.១០០ ដុល្លារ

៣-លោក **សុខ ស៊ីណារី** សប្បុរសជននៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១៣.៦៤៨ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ធ្នូ ឆ្នាំ ២០០៦

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៧០១...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រី នគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៧៤ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០០៦ ស្តីពីការកែសំរួលព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥ /៦៥ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- យោងតាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោកវរៈសេនីយ៍ឯក **រស់ សាផល** ជាជំនួយការឯកឧត្តមអនុប្រធានអចិន្ត្រៃយ៍អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានឋានៈស្មើ**ប្រធាននាយកដ្ឋាន** ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ពន្ធ័ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានី ភ្នំពេញ ថ្ងៃទី ០៦ [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:......៩១០២.....អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនអ្នកជំនាញការ អង្គការ KOICA កូរ៉េ ចំនួន ០២រូប ដែលមានស្នាដៃល្អ ក្នុងការសម្របសម្រួលអនុវត្តន៍គំរោងកសាងបង្គោលបណ្តាញប្រើថពិរិភាគ នៅកម្ពុជា ជំហានទី២ ក្នុងខេត្តពោធិ៍សាត់ និង តំបន់ជុំវិញ ដូចមានរាយនាមខាងក្រោម :-

១-លោក **Kim Yongpyo** តំណាង **KOICA**

២-លោក **Chung Yong Sik** នាយកប្រតិបត្តិគំរោង របស់ក្រុមហ៊ុន **Samboo Engineering Co. Ltd**

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។/។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:......៨០៣......អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **Auh Su chang** អ្នកបច្ចេកទេសនៃក្រុមហ៊ុន **Samboo Engineering Co.Ltd** និងជាប្រធានក្រុមការងារអនុវត្តគំរោង ដែលបានខិតខំប្រឹងប្រែងយ៉ាងសកម្ម ក្នុងការអនុវត្តន៍គំរោងកសាងបង្គោលបណ្តាញប្រើថពីរភាគ នៅកម្ពុជា ជំហានទី២ ក្នុងខេត្តពោធិ៍សាត់ និងតំបន់ជុំវិញ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។៚

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ... ឆ្នាំ ២០០៦

ហ៊ុន សែន

អន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥០៤ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយការងារ
តាមលំដាប់ថ្នាក់

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងទេសចរណ៍

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន ១២៤ រូប នៃក្រសួងទេសចរណ៍ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចកន្លងមក ដូចមានរាយនាមខាងក្រោម :-

ក. មេដាយមាសការងារ :

០១-	លោក	សៀង តឹមហាន	អគ្គនាយករងទេសចរណ៍
០២-	លោក	មុី ម៉ារ៉ាឌី	ប្រធាននាយកដ្ឋានស្ថិតិ និងពត៌មាន
០៣-	លោក	សយ សាខន	អធិការរង
០៤-	លោក	ប្រាក់ ច័ន្ទតារា	អនុប្រធាននាយកដ្ឋានអប់រំបណ្តុះបណ្តាល
០៥-	លោកស្រី សា	ឿន	អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌
០៦-	លោក	អ៊ុំ ឃីម	អនុប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍
០៧-	លោក	ភួង វណ្ណៈ	អនុប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍
០៨-	លោក	សំ វុទ្ធា	អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ
០៩-	លោក	សយ ផល្លា	អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន
១០-	លោក	គង់ សុភារក្ស	អនុប្រធាននាយកដ្ឋានពត៌មានទេសចរណ៍
១១-	លោក	កើត ពុទ្ធរី	អនុប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍
១២-	លោក	ហ៊ុយ ភីរក្ស	អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន
១៣-	លោក	យិន ស៊ីផេង	អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារនិងផ្សព្វផ្សាយ

១៤-	លោក	ខៀវ ថានវិចារ	អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារនិងផ្សព្វផ្សាយ
១៥-	លោក	ថៃ ដារារិទ្ធ	ប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ធំ
១៦-	លោក	អៀវ មុំងដែន	ប្រធានមន្ទីរទេសចរណ៍ខេត្តក្រចេះ
១៧-	លោក	នាយ ខឿន	ប្រធានមន្ទីរទេសចរណ៍ក្រុងកែប
១៨-	លោក	ត្រា នុតស៊ាន	ប្រធានមន្ទីរទេសចរណ៍ខេត្តរតនគីរី
១៩-	លោក	ពេញ ពន្លក	នាយការិ. នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
២០-	លោក	គង់ ប៊ុណ្ណារ័ត្ន	នាយការិ. នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
២១-	លោក	កែវ វាសនា	នាយការិ. នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
២២-	លោក	កែវ សិរីវុធ	អនុប្រធានមន្ទីរទេសចរណ៍ខេត្តពោធិសាត់
២៣-	លោក	ស៊ាន សុគុន	អនុប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ចាម
២៤-	លោក	ម៉ូវ សេងកាក់	អនុប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប
២៥-	លោក	ឯល ណារី	អនុប្រធានមន្ទីរទេសចរណ៍ក្រុងកែប
២៦-	លោក	អ៊ិន ប្រាជ្ញ	អនុប្រធានមន្ទីរទេសចរណ៍ខេត្តបាត់ដំបង
២៧-	លោក	អ៊ូង លាន	អនុប្រធានមន្ទីរទេសចរណ៍ក្រុងប៉ៃលិន
២៨-	លោក	ទូច មានី	នាយរងការិ. នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
២៩-	លោក	នូ ណូរ៉ា	នាយរងការិ. នាយកដ្ឋានឧស្សាហកម្មទេសចរណ៍
៣០-	លោក	ចែម សំបូរ	នាយរងការិ. នាយកដ្ឋានឧស្សាហកម្មទេសចរណ៍
៣១-	លោក	សុខ នួន	នាយរងការិ. នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
៣២-	លោក	មាស ប៊ុំលីកា	នាយរងការិ. នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
៣៣-	លោក	អ៊ឹម ស៊ីនណារិទ្ធ	នាយរងការិ. នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
៣៤-	លោកស្រី	ស៊ឹម សុភាព	នាយរងការិ. នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
៣៥-	លោក	ប៊ូ អេង	ប្រធានការិ. មន្ទីរទេសចរណ៍ខេត្តកោះកុង
៣៦-	លោក	ប៉ែន មុន្នី	អនុប្រធានការិ.មន្ទីរទេសចរណ៍រាជធានីភ្នំពេញ
៣៧-	លោក	កួច ហាក់ស្រុង	មន្ត្រីការិ. មន្ទីរទេសចរណ៍ខេត្តកណ្តាល
៣៨-	លោក	ប៊ុល សៃ	មន្ត្រីការិ. មន្ទីរទេសចរណ៍ខេត្តបាត់ដំបង
៣៩-	លោក	សាន់ សារិន	មន្ត្រីការិ. មន្ទីរទេសចរណ៍ខេត្តកំពង់ចាម

ខ.មេដាយថ្នាក់សំរឹទ្ធ :

០១-	លោក	ឈុន ណាក់	អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន
០២-	លោកស្រី	តឹក សុភី	អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និង ផ្សព្វផ្សាយ
០៣-	លោក	ហេង មករា	អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
០៤-	លោក	លីវ វណ្ណហេង	អនុប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍
០៥-	លោក	សួស សារ៉ន	នាយការិ. នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
០៦-	លោក	ស្រ៊ន សុវណ្ណារ៉ា	នាយការិ. នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌
០៧-	លោកស្រី	ហែន សុខារី	នាយការិ. នាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍
០៨-	លោក	សោម ប៊ុនណាត	នាយការិ. នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន
០៩-	លោក	ហ៊ុន វិសាល	នាយខុទ្ទកាល័យរដ្ឋមន្ត្រី
១០-	លោក	គីម ចាន់ណារ៉ុធ	នាយរងការិ. នាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ
១១-	លោក	ឈឿន សេរីវុធ	អនុប្រធានមន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ
១២-	លោក	គង់ ចាន់ថា	អនុប្រធានមន្ទីរទេសចរណ៍ខេត្តឧត្តរមានជ័យ
១៣-	លោក	ដួង ហេង	អនុប្រធានមន្ទីរទេសចរណ៍ខេត្តតាកែវ

១៤-	លោក ស៊ុន សឿង	អនុប្រធានមន្ទីរទេសចរណ៍ខេត្តតាកែវ
១៥-	លោក សយ ស៊ីណុល	អនុប្រធានមន្ទីរទេសចរណ៍ខេត្តកំពត
១៦-	លោក ជុង សុខេមរៈ	អនុប្រធានមន្ទីរទេសចរណ៍ខេត្តឧត្តរមានជ័យ
១៧-	លោកស្រី អេង ណារី	អនុប្រធានមន្ទីរទេសចរណ៍ខេត្តព្រៃវែង
១៨-	លោក សុខ វណ្ណៈ	អនុប្រធានមន្ទីរទេសចរណ៍ក្រុងកែប
១៩-	លោក សេង ហុង	អនុប្រធានមន្ទីរទេសចរណ៍ខេត្តពោធិសាត់
២០-	លោក ជេត សុផល	អនុប្រធានមន្ទីរទេសចរណ៍ខេត្តពោធិសាត់
២១-	លោក ងិន សុវិមាន	អនុប្រធានមន្ទីរទេសចរណ៍ខេត្ត មណ្ឌលគិរី
២២-	លោក សោ វិសិដ្ឋ	អនុប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប
២៣-	លោក គីម ភារី	អនុប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប
២៤-	លោក ពុទ្ធ យុទ្ធ	អនុប្រធានមន្ទីរទេសចរណ៍ខេត្តស្វាយរៀង
២៥-	លោក នឹម ឆន	ប្រធានការិ. មន្ទីរទេសចរណ៍ខេត្តសៀមរាប
២៦-	លោក សេង សាលី	ប្រធានការិ. មន្ទីរទេសចរណ៍ខេត្តកំពង់ឆ្នាំង
២៧-	លោកស្រី ស៊្រុំ ឌី	ប្រធានការិ. មន្ទីរទេសចរណ៍ក្រុងប៉ៃលិន
២៨-	លោក ទ្រី សារ៉ាត	ប្រធានការិ. មន្ទីរទេសចរណ៍ខេត្តព្រៃវែង
២៩-	លោក យិន ណាត	នាយការិ. នាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍
៣០-	លោក នុត សុខា	នាយការិ. នាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍
៣១-	លោក សំ សីឌី	នាយរងការិ. នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌
៣២-	កញ្ញា លន ណារី	នាយរងការិ. នាយកដ្ឋានអប់រំបណ្តុះបណ្តាល
៣៣-	លោកស្រី និន វីរយ៉ា	នាយរងការិ. នាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍
៣៤-	កញ្ញា គង់ រត្នលំអង	នាយរងការិ. នាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ
៣៥-	លោក នឹម សុវណ្ណ	នាយរងការិ. នាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ
៣៦-	លោក ម៉ម ម៉ានីវឌ្ឍ	នាយរងការិ. នាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ
៣៧-	លោក សុខ វណ្ណា	នាយរងការិ. នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌
៣៨-	លោក ជា ចាន់ហេង	នាយរងការិ. នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
៣៩-	លោក ទូន សេដា	នាយរងការិ. នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
៤០-	លោក ឈៀង ពុទ្ធា	នាយរងការិ. នាយកដ្ឋានឧស្សាហកម្មទេសចរណ៍
៤១-	អ្នកស្រី តាន់ ឆៃវណ្ណា	អនុប្រធានការិ.មន្ទីរទេសចរណ៍ខេត្តសៀមរាប
៤២-	លោក ធន់ ចាន់នី	អនុប្រធានការិ.មន្ទីរទេសចរណ៍ខេត្តសៀមរាប
៤៣-	លោក សុខ អាង	អនុប្រធានការិ.មន្ទីរទេសចរណ៍ខេត្តព្រៃវែង
៤៤-	លោក វិន មុនីវឌ្ឍនះ	មន្ត្រីអគ្គនាយកដ្ឋានទេសចរណ៍
៤៥-	អ្នកស្រី គុណ ពុធីតា	មន្ត្រីការិ. នាយកដ្ឋានឧស្សាហកម្មទេសចរណ៍
៤៦-	អ្នកស្រី ឯម វ៉ាន់សារ៉ារត្ន័	នាយរងការិ. នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
៤៧-	អ្នកស្រី ព្រំ សុភារិន	មន្ត្រីការិ. នាយកដ្ឋានឧស្សាហកម្មទេសចរណ៍

គ-មេដាយសំរឹទ្ធ ការងារ :

០១-	លោក	ច្រឡឹង សុមេធា	អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង អាស៊ាន
០២-	លោក	នុត នារក្ស	អនុប្រធាននាយកដ្ឋានស្ថិតិ និង ពត៌មាន
០៣-	លោក	ឡោ ធូរ៉ា	ជំនួយការឯកឧត្តមរដ្ឋមន្ត្រី
០៤-	លោកស្រី	នុប សុចន្និទ្រ	នាយការិ. នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌
០៥-	លោក	គុជ សុពល	នាយរងការិ. នាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ
០៦-	លោក	សៅ សារបុត្រ	នាយរងការិ. នាយកដ្ឋានអប់រំបណ្តុះបណ្តាល
០៧-	លោក	ម៉ុញ ទី	នាយរងការិ. នាយកដ្ឋានស្ថិតិ និងពត៌មាន
០៨-	លោក	ឡាយ សោភ័ណ្ឌ	នាយរងការិ.នាយកដ្ឋានអប់រំបណ្តុះបណ្តាល
០៩-	លោក	ស្រី ទឹម សម្បុរី	នាយរងការិ.នាយកដ្ឋានអប់រំបណ្តុះបណ្តាល
១០-	លោក	ចាយ សុរិទ្ធ	នាយរងការិ.នាយកដ្ឋានសិក្សាទីផ្សារនិងផ្សព្វផ្សាយ
១១-	លោក	ប៊ុន ហេង	អនុប្រធានការិ.មន្ទីរទេសចរណ៍ខេត្តកណ្តាល
១២-	អ្នកស្រី	គួច ចន្ថា	អនុប្រធានការិ.មន្ទីរទេសចរណ៍ក្រុងព្រះសីហនុ
១៣-	លោក	គ្រោត តឹមមាង	អនុប្រធានការិ.មន្ទីរទេសចរណ៍ភ្នំពេញ
១៤-	លោក	ឈឹម ជន	អនុប្រធានការិ.មន្ទីរទេសចរណ៍ពោធិសាត់
១៥-	លោក	ខែត សំអាត	អនុប្រធានការិ.មន្ទីរទេសចរណ៍ពោធិសាត់
១៦-	លោក	អ៊ុក សាន	អនុប្រធានការិ.មន្ទីរទេសចរណ៍ខេត្តកំពង់ធំ
១៧-	អ្នកស្រី	ស៊ំឌី សិទ្ធី	អនុប្រធានការិ.មន្ទីរទេសចរណ៍ខេត្តសៀមរាប
១៨-	លោក	លី សារ៉េត	អនុប្រធានការិ.មន្ទីរទេសចរណ៍ខេត្តសៀមរាប
១៩-	លោក	ជុំ សេន	អនុប្រធានការិ.មន្ទីរទេសចរណ៍ខេត្តកណ្តាល
២០-	អ្នកស្រី	ទឹម ស៊ីម៉ុន	មន្ត្រីការិ. នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
២១-	លោក	ណែម ស៊ីវឌ្ឍនា	មន្ត្រីការិ. នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
២២-	លោក	ពៅ រ៉ា	មន្ត្រីការិ. នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
២៣-	កញ្ញា	ហ៊ីង ច័ន្ទបុប្ផា	មន្ត្រីការិ. នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
២៤-	លោក	ឡេង ពីឡុត	មន្ត្រីការិ. នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
២៥-	អ្នកស្រី	ប៉ាត់ សុជាតា	មន្ត្រីការិ. នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
២៦-	លោក	ម៉ិច ជាត់ប្រណិត	មន្ត្រីការិ. មន្ទីរទេសចរណ៍ខេត្តកណ្តាល
២៧-	លោក	ស្រី ម៉ារ៉ាឌី	មន្ត្រីការិ. នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
២៨-	អ្នកស្រី	លិះ លៀប	មន្ត្រីការិ. មន្ទីរទេសចរណ៍ខេត្តសៀមរាប
២៩-	អ្នកស្រី	មុត ផល្លីន	មន្ត្រីការិ. មន្ទីរទេសចរណ៍ខេត្តសៀមរាប
៣០-	លោក	ហេង សារៈ	មន្ត្រីការិ. មន្ទីរទេសចរណ៍ខេត្តសៀមរាប
៣១-	លោក	សុខ សោម	មន្ត្រីការិ. មន្ទីរទេសចរណ៍ខេត្តសៀមរាប
៣២-	លោក	ហុក ហួន	មន្ត្រីការិ. មន្ទីរទេសចរណ៍ខេត្តសៀមរាប
៣៣-	កញ្ញា	ម៉ឹក ពុទ្ធារី	មន្ត្រីការិ. មន្ទីរទេសចរណ៍ខេត្តសៀមរាប
៣៤-	កញ្ញា	យ៉ាន់ ភារី	មន្ត្រីការិ. មន្ទីរទេសចរណ៍ខេត្តកំពង់ចាម
៣៥-	អ្នកស្រី	អ៊ុំ សុគន្ធារី	មន្ត្រីការិ. មន្ទីរទេសចរណ៍ខេត្តតាកែវ
៣៦-	លោក	ម៉ុក សេកាល្វ	មន្ត្រីការិ. មន្ទីរទេសចរណ៍ខេត្តកំពត

៣៧- កញ្ញា ជិន សុភះឡា មន្ត្រីការិ. មន្ទីរទេសចរណ៍ខេត្តកំពត

៣៨- កញ្ញា អ៊ុយ សំអុន មន្ត្រីការិ. នាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ធ្នូ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:......១១០៥...អនក្រ.ទត

អនុក្រឹត្យ
ស្តីពីការជូនមេដាយសុវត្ថារា
៖៚
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងទេសចរណ៍

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន ៣២ រូប នៃក្រសួងទេសចរណ៍ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចកន្លងមក ដូចមានរាយនាមខាងក្រោម :-

ក-មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ :

០១-	ឯកឧត្តម	អ៊ុក ស៊ីផាន	អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ
០២-	ឯកឧត្តម	រ៉ុត ចាន់ថា	ប្រធាននាយកដ្ឋានអប់រំបណ្តុះបណ្តាល
០៣-	លោក	ទិត ចន្ថា	អគ្គនាយករងទេសចរណ៍
០៤-	លោក	ហោ សារុន	អគ្គនាយករង និងជាប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ
០៥-	លោក	ខួង វីរៈ	ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស
០៦-	លោក	យ៉ង វិន	ប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍
០៧-	លោក	រស់ សំអ៊ា	ប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍
០៨-	លោក	ប៉ាក់ សុខុម	ប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ
០៩-	លោក	សៅ សារឿន	អធិការ
១០-	លោក	តេង ប៊ុយ	ប្រធានមន្ទីរទេសចរណ៍ក្រុងព្រះសីហនុ
១១-	លោក	កែន សាគុណ	អនុប្រធាននាយកដ្ឋាន អភិវឌ្ឍន៍ទេសចរណ៍វប្បធម៌

ខ. គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ អស្សឫទ្ធិ

០១-	ឯកឧត្តម	ជង់ ឡឹម	ទីប្រឹក្សាសម្តេច ហេង សំរិន និងជាប្រធានមន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ
០២-	លោក	អ៊ុក សុខា	អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ
០៣-	លោក	ឈឹម វណ្ណថា	អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ
០៤-	លោកស្រី	ហូ សុជានី	អនុប្រធាននាយកដ្ឋានរដ្ឋបាល នឹង កិច្ចការទូទៅ
០៥-	លោក	ម៉ៅ សុចិត្រា	អនុប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស
០៦-	លោកស្រី	ឈួក ឈុវង្ស	អនុប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស
០៧-	លោក	សុង តុងហាប់	អនុប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ
០៨-	លោក	ឡឹក យ៉ែម	អនុប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ
០៩-	លោកស្រី	ចាន់ សារីជឹង	អនុប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ
១០-	លោក	គង់ សូលីដា	អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន
១១-	លោក	ចិន សាម៉ន	ប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ
១២-	លោក	ប៉ុង យ៉េន	ប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ចាម
១៣-	លោក	កុយ សង	ប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប
១៤-	លោក	ញ៉ូវ សុង	ប្រធានមន្ទីរទេសចរណ៍ខេត្តពោធិ៍សាត់
១៥-	លោក	ហ៊ុន សារឿន	ប្រធានមន្ទីរទេសចរណ៍ខេត្តតាកែវ
១៦-	លោក	ជុន ម៉េង	ប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ស្ពឺ
១៧-	លោក	ពៅ សុខន	ប្រធានមន្ទីរទេសចរណ៍ខេត្តកណ្តាល
១៨-	លោក	ណែម ស៊ីនួន	ប្រធានមន្ទីរទេសចរណ៍ខេត្តកំពត
១៩-	លោក	ប៊ុន បៀវ	ប្រធានមន្ទីរទេសចរណ៍ខេត្តកោះកុង
២០-	លោក	សេង លីថេង	ប្រធានមន្ទីរទេសចរណ៍ក្រុងប៉ៃលិន
២១-	លោក	ជុំ ជួន	អនុប្រធានមន្ទីរទេសចរណ៍ខេត្តកណ្តាល

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ ៚

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៦

ហ៊ុន សែន

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:......៥៤០......អនក្រ-តត [illegible]

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនចំពោះ **Mrs. Reny Andrie** ភរិយារបស់អនុព័ន្ធយោធាឥណ្ឌូណេស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃល្អក្នុងការលើកស្ទួយទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងពីរ កម្ពុជា-ឥណ្ឌូណេស៊ី ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ជូនសប្បុរសជនចំនួន **១៤ នាក់ ដែលបានយកអស់**កំលាំងកាយចិត្ត និង បានបរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយក**សាងហេដ្ឋារចនាសម្ព័ន្ធ**លើ**គ្រប់វិស័យ**នៅស្រុកចន្ទ្រា ខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោម :

ក - មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** :

១- លោកឧត្តមសេនីយ៍ទោ **ឡាញ់ គៅ**
២- លោកឧត្តមសេនីយ៍ទោ **សោម សុធា**
៣- លោកឧត្តមសេនីយ៍ទោ **គាន់ ផានណារា**
៤- លោកឧត្តមសេនីយ៍ទោ **អ៊ុំ ផាន់សារី**
៥- លោកឧត្តមសេនីយ៍ទោ **សោម សារុម**
៦- លោកឧត្តមសេនីយ៍ទោ **ទាប ភក្តី**
៧- លោកឧត្តមសេនីយ៍ទោ **ឈី សុវណ្ណា**
៨- លោកឧត្តមសេនីយ៍ត្រី **អៀង ផល្លាច**
៩- លោកឧត្តមសេនីយ៍ត្រី **ម៉ុល និត**

ខ - មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** :

១- លោក **ឈួក បណ្ឌិត**
២- លោកវរសេនីយ៍ឯក **សូ សាម៉ន**
៣- លោកវរសេនីយ៍ឯក **រ៉ែត្ន មុន្នី**
៤- លោក **សុខ្ញ គឹមចំន្ទ**
៥- លោកវរសេនីយ៍ឯក **អន ស៊ាង**

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបាន លទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ១៧៨៥ ឧរថ.កឧ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៦

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញប្រកាសលេខ ៤៩៤ ឧរថ.កឧ.ប្រក ចុះថ្ងៃទី ០៤.០៧.២០០៥ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ២៧៩៦/០៥ ក.អ.ក ចុះថ្ងៃទី ១៥.០៨.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ហូយៀ (ខេមបូឌា) ហ្គាមេន លីមីធីត ចុះថ្ងៃទី២៦.១០.២០០៦

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ហូយៀ (ខេមបូឌា) ហ្គាមេន លីមីធីត (HOYEAR (CAMBODIA) GARMENT LIMITED.) តំណាងដោយលោក CHENG YAM KEE សញ្ជាតិចិន អាយុ៥៦ឆ្នាំ កាន់លិខិតឆ្លងដែនលេខ HA9064207 ចុះថ្ងៃទី២៦.០៤.២០០៥ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់នាំចេញ" ដែលមានឈ្មោះថា "ហូយៀ (ខេមបូឌា) ហ្គាមេន លីមីធីត សាខាទី១ (HOYEAR (CAMBODIA) GARMENT LIMITED BRANCH No 1)" មានទីតាំងស្ថិតនៅផ្លូវលេខ៣៦៩ ភូមិអណ្តូងទឹក សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការរោងចក្រ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រ ទៅតាមប្លង់ដែលបានតំកល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រ នេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់ "ហើយត្រូវផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា ១៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និង បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល ១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចូនចូរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ហូយៀ (ខេមបូឌា) ហ្គាមេន លីមីធីត ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

" ដើម្បីជូនជ្រាប "

- ដូចប្រការ ៩ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ១៧៤៨ ឧរថ.កឧ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៦

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី ២៣.០៦.២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញប្រកាសលេខ ០០២ ឧរថ.កឧ.ប្រក ចុះថ្ងៃទី ០២.០១.២០០៤ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ២៣៨ ឧរថ.កឧ.លស ចុះថ្ងៃទី០៩.០២.២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ១០៧៥ ឧរថ.កឧ.លស ចុះថ្ងៃទី ០២.០៧.២០០៤ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ១៣៧៤/០៤.ត.វ.ក ចុះថ្ងៃទី ២៧.០៥.២០០៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ម៉ាកាឡុត ហ្គាមេន (ខេមបូឌា) ចុះថ្ងៃទី០៦.១២.២០០៦

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ម៉ាកាឡុត ហ្គាមេន (ខេមបូឌា) (MAKALOT GARMENTS (CAMBODIA) CO., LTD.) តំណាងដោយលោក CHANG, YEN-KAI សញ្ជាតិចិន(តៃវ៉ាន់) អាយុ៦២ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 133071620 ចុះថ្ងៃទី០៧.០៣.២០០២ បង្កើតសាខារោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "ម៉ាកាឡុត ហ្គាមេន (ខេមបូឌា) សាខាទី១ (MAKALOT GARMENTS (CAMBODIA) BRANCH N° 1)" មានទីតាំងស្ថិតនៅ ក្នុងសួនឧស្សាហកម្មវឌ្ឍនៈ អាគារ "H" ផ្លូវបោមចៅ ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ២: ក្នុងកិច្ចដំណើរការរោងចក្រ ក្រុមហ៊ុន ត្រូវរៀបចំរោងចក្រទៅតាមប្លង់ដែលបានតំកល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រ នេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់ " ហើយត្រូវផ្តល់ទិន្នន័យ និង របាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា១៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និង បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល ១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ម៉ាកាឡូត ហ្គាមេន (ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ១៧៨៩ ឧរថ.កឧ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ២០០៦

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី ២៣.០៦.២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញប្រកាសលេខ ០០២ ឧរថ.កឧ.ប្រក ចុះថ្ងៃទី ០២.០១.២០០៤ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ២៣៨ ឧរថ.កឧ.លស ចុះថ្ងៃទី០៩.០២.២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ១៤៤ ឧរថ.កឧ ចុះថ្ងៃទី ២៦.០១.២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ១១១/០៦ ត.វ.ក ចុះថ្ងៃទី ១០.០១.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ម៉ាកាឡូត ហ្គាមេន (ខេមបូឌា) ចុះថ្ងៃទី០៦.១២.២០០៦

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ម៉ាកាឡូត ហ្គាមេន (ខេមបូឌា)(MAKALOT GARMENTS (CAMBODIA) CO., LTD.) តំណាងដោយលោក CHANG, YEN-KAI សញ្ជាតិចិន(តៃវ៉ាន់) អាយុ៦២ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 133071620 ចុះថ្ងៃទី០៧.០៣.២០០២ បង្កើតសាខារោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "ម៉ាកាឡូត ហ្គាមេន (ខេមបូឌា) សាខាទី២ (MAKALOT GARMENTS (CAMBODIA) BRANCH N° 2)" មានទីតាំងស្ថិតនៅក្នុងសួនឧស្សាហកម្មវឌ្ឍនៈ អាគារ "O" ផ្លូវចោមចៅ ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ :(៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការរោងចក្រ ក្រុមហ៊ុន ត្រូវរៀបចំរោងចក្រទៅតាមប្លង់ដែលបានតំកល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រ នេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់ " ហើយត្រូវផ្តល់ទិន្នន័យ និង របាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា១៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ជូនក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និង បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១ក្នុងរយៈពេល ១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះខ្លឹមប្រការ ណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ម៉ាកាឡូត ហ្គាមេន (ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៦៧៩០ ឧរថ.កឧ.-ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ២០០៦

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី ២៣.០៦.២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញប្រកាសលេខ ០០២ ឧរថ.កឧ.ប្រក ចុះថ្ងៃទី ០២.០១.២០០៤ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ២៣៨ ឧរថ.កឧ.លស ចុះថ្ងៃទី០៩.០២.២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣២៣៩/០៦ ត.វ.ក ចុះថ្ងៃទី ២៥.០៨.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ម៉ាកាឡូត ហ្គាមេន (ខេមបូឌា) ចុះថ្ងៃទី០៦.១២.២០០៦

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ម៉ាកាឡូត ហ្គាមេន (ខេមបូឌា) (MAKALOT GARMENTS (CAMBODIA) CO., LTD.) តំណាងដោយលោក CHANG, YEN-KAI សញ្ជាតិចិន(តៃវ៉ាន់) អាយុ៦២ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 133071620 ចុះថ្ងៃទី០៧.០៣.២០០២ បង្កើតសាខារោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "ម៉ាកាឡូត ហ្គាមេន (ខេមបូឌា) សាខាទី៣ (MAKALOT GARMENTS (CAMBODIA) BRANCH Nº 3)" មានទីតាំងស្ថិតនៅក្នុងសួនឧស្សាហកម្មវឌ្ឍនះ អាគារ "I" ផ្លូវលោមចៅ ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ :(៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការរោងចក្រ ក្រុមហ៊ុន ត្រូវរៀបចំរោងចក្រទៅតាមប្លង់ដែលបានតំកល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រ នេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវផ្តល់ទិន្នន័យ និង របាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា១៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ជូនក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និង បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១គ្នាក្នុងរយៈពេល ១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះប្រការ ណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ម៉ាកាឡូត ហ្គាមេន (ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ ៩ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ១៧២១ ប្រ.ក

ប្រកាស
ស្តីពី
ការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយ

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៦/១២២ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
-បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
-បានឃើញអនុក្រឹត្យ លេខ១៦អ.ន.ក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
-តាមសំណើ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់ លោក ថោង សុវណ្ណារ៉ា ប្រធាន **គណបក្សសង្គមប្រជាធិបតេយ្យ** អក្សរកាត់ **គ.ស.ប** ។

សំរេច

ប្រការ១ : ត្រូវបានចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ **គណបក្សសង្គមប្រជាធិបតេយ្យ** ដែលមានទីស្នាក់ការកណ្តាលតាំងនៅផ្ទះលេខ A៦៨ ផ្លូវលេខ VI-១៦ សង្កាត់ ទួលសង្កែ ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ២ : អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល និងគណបក្សសង្គមប្រជាធិបតេយ្យ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០០៦

កន្លែងទទួល :
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
"ដើម្បីជូនជ្រាប"
-គ្រប់សាលាខេត្ត-ក្រុង
-ដូចប្រការ២
"ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ